# ប្រវត្តិពុទ្ធសាសនា

ក្រោយ

# ព្រះពុទ្ធបរិនិព្វាន

ដោយ

ព្រះគ្រូឃោសាភិរតំ លាស់_ឡាយ

វត្តមហាមន្ត្រី ភ្នំពេញ

ព ស ២៥០៨

LIBRARY
BUDDHIST INSTITUTE

បោះពុម្ពលើកនេះចំនួន ១,០០០ ច្បាប់
ព,ស ២៥៣៩ គ,ស ១៩៩៥
ចែកជាធម្មទាន

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ស្រុង ចាន់ណា** ម្ចាស់គេហទំព័រ៥000ឆ្នាំ

សូមគោរពថ្លែងអំណរគុណចំពោះ

**លោកវេជ្ជបណ្ឌិត ខ្ញៅ ឃុនសំរ៉ង** ជាប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា** www.ceefoundation.org

និង **ករុណាខ្មែរ** www.karunacambodia.org

ដែលបានអនុញ្ញាតដល់គេហទំព័រ៥000ឆ្នាំ

យកសៀវភៅនេះមកដាក់ផ្សាយបន្តជាធម្មទាន

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ ។

បណ្ណាល័យអេឡិចត្រូនិចខ្មែរ
eLibrary of Cambodia
www.elibraryofcambodia.org

# ប្រវត្តិពុទ្ធសាសនា

ក្រោយ

# ព្រះពុទ្ធបរិនិព្វាន

ដោយ

ព្រះគ្រូឃោសាភិរត៌ លាស់_ឡាយ

វត្តមហាមន្ត្រី ភ្នំពេញ

ពស ២៥០៨

បោះពុម្ពលើកនេះចំនួន ១,០០០ ច្បាប់

ព.ស ២៥៣៩ គ.ស ១៩៩៥

ចែកជាធម្មទាន

www.budinst.gov.kh www.elibraryofcambodia.org



១៩៥៥ : ព្រះជន្មាយុ ៨១ ឆ្នាំ

សម្ដេចព្រះធម្មលិខិត លោស់ ឡាយ

ប្រធានថេរសភា នៃ រាជាណាចក្រកម្ពុជា

និងជា

អនុគណ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ

www.budinst.gov.kh www.elibraryofcambodia.org

សៀវភៅ " ប្រវត្តិពុទ្ធសាសនា និងគាថាព្រះពុទ្ធ
បរិនិព្វាន " នេះខ្ញុំបាទប្រគល់ជូនឧបាសក ម៉ៅ ប៊ុន
ដើម្បីគិតគួររៀបចំបោះពុម្ព តាមសទ្ធាជ្រះថ្លារបស់គាត់
និង ពុទ្ធបរិស័ទទាំងឡាយទាំងពួងផង ។

ហេតុនេះ ខ្ញុំសូមលើកផងសេចក្ដីប្រកាសអររីករាយ
សប្បាយផងអនុមោទនា ចំពោះគំនិតដ៏ប្រសើរ និង កុសលកម្ម
ដ៏វិសុទ្ធផ្លានោះ ហើយសូមប្រគល់សិទ្ធិជូនឧបាសក ម៉ៅ ប៊ុន
បោះពុម្ពសៀវភៅនេះបានតាមបំណងប្រាថ្នា ។

វត្តបទុមក្រុងភ្នំពេញ , ថ្ងៃ ព្រហស្បតិ៍ ១រោច ខែ កត្តិក ព.ស ២៥០៨ ត្រូវនឹងថ្ងៃទី ០១ ខែ ធ្នូ គ.ស ១៩៦៤

សម្ដេចព្រះធម្មលិខិត លាស់ ឡាយ
ប្រធានថេរសភា នៃ រាជាណាចក្រកម្ពុជា
អនុគណៈមណ្ឌលរាជធានីភ្នំពេញ

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
៦៥៩/៥៥
04-10

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh**        **www.elibraryofcambodia.org**

# អារម្ភកថា

អត្ថបទ-ចំណុចនៃសេចក្តីអត្ថាធិប្បាយក្នុងសៀវភៅនេះ ខ្ញុំឲ្យឈ្មោះថាប្រវត្តិពុទ្ធសាសនាក្រោយព្រះពុទ្ធបរិនិព្វាន, ព្រោះសាច់រឿងជាប់ទាក់ទងទៅពុទ្ធសាសនា ក្រោយព្រះពុទ្ធបរិនិព្វានជាយច្រើន ។

ការប្រព្រឹត្តទៅ ឬរីកសាយនៃព្រះពុទ្ធសាសនា មិនមែនមានជោគវាសនា ត្រឹមតែធម្មវិន័យនោះទេ ប៉ុន្តែការពិសេសបំផុតគឺមនុស្ស. មនុស្សអ្នកបញ្ញត្តសាសនា, មនុស្សអ្នកប្រតិបត្តិ និងពង្រីកសាសនា ឲ្យមានធម្មរស្មីគ្រប់ទិសទី ។

បើគេក្រឡេកមើលតាមដំបន់ ឬទ្វីបនីមួយ ១ នោះគេឃើញគោលជាតិនៃពុទ្ធសាសនា ជាក់ត្រង់មានតែក្នុងជម្ពូទ្វីបទេ ក្នុងសម័យពុទ្ធកាល ហើយមិនបានប្រព្រឹត្តទៅសព្វដំបន់ផង គឺសម័យពុទ្ធកាល ពុទ្ធសាសនាផ្សាយមានក្នុងតែជម្ពូទ្វីប តែក្នុងតំណៀងទាំងអស់នេះទេ ហើយបានតែ៧រដ្ឋប៉ុណ្ណោះគឺៈ ១–រដ្ឋកាសីនិងកោសល (ក្រុងពារាណសីនិងសាវត្ថី), ២–រដ្ឋមគធៈនិងអង្គៈ (ក្រុងរាជគ្រឹះនិងចម្បា), ៣ សក្ករដ្ឋ ក្រុង–

www.budinst.gov.kh www.elibraryofcambodia.org

កបិលពស្តុ) ៤-វជ្ជីរដ្ឋ (ក្រុងវេសាលី), ៥-មល្លរដ្ឋ (ក្រុងបាវា ឬកុសិនារា), ៦-វង្សរដ្ឋ(ក្រុងកោសម្ពី), ៧-កុរុរដ្ឋ(ក្រុងឥន្ទបត្ត)ៗ

លុះសម័យក្រោយធ្វើតតិយសង្គាយនារួច ទើបពុទ្ធសាសនាក៏ចំព្រើកខ្ជូរអានុភាពរបស់ខ្លួន ឡើងកិលបូលទៅក្នុងរដ្ឋដ៏ទៃៗនាជម្ពូទ្វីបនេះទៀត, ដូចជារដ្ឋកស្មីរនិងគន្ធារ ( សាគលនិងបាគិស្ថាន), រដ្ឋមហិសកមណ្ឌល(មីសោរ៍), រដ្ឋវនវាសី(កនរ), រដ្ឋអបរន្តក: (គុជរ័តខាងជើងនិងកច្ឆាក់-សិន្ធុ), មហារដ្ឋ (ឥណ្ឌៀកណ្តាល) រដ្ឋយោនក: (កាហ្វុបាគានិស្ថាន), ដំបន់មហាមពាគ្គនិងសុវណ្ណភូមិ (កៀរក្កុំហាមាលយានិងស្រុកមន ។

កាលដែលធ្វើតតិយសង្គាយនារួចនោះ ពុទ្ធសាសនាមិនត្រឹមតែបានផ្សាយនូវធម្មរស្មី ទៅក្នុងរដ្ឋនិងដំបន់នាជម្ពូទ្វីបនេះប៉ុណ្ណោះទេ ថែមទាំងរសាត់អណ្តែតទៅប្រតិស្ឋានជាក់មូសជាប់ក្នុងលង្កាទ្វីបទៀតផង ។

សម័យក្រោយពុទ្ធកាលនោះ ពុទ្ធសាសនាបានវិតកាលទៅក្នុងទិសទី ច្រើនកន្លែងក៏ពិតមែន ប៉ុន្តែមិនទាន់ច្បាស់ជា

www.budinst.gov.kh www.elibraryofcambodia.org

មានដំហារ៉ិនប៉ុន៏នៅឡើយទេ ព្រោះធម្មវិន័យនៅបេះតែក្នុងមាត់ព្រះសង្ឃនិងមនុស្សម្នាក់ ៗ មិនទាន់បានចារជាក់ក្នុងក្បួនច្បាប់ជាសាធារណៈឲ្យជាប់ជាស្ថាពរនៅឡើយ ម្ល៉ោះហើយ ពុទ្ធបរិស័ទបេះតែមានយោបល់បែកបាក់គ្នាជាច្រើនលើក ៗ

អពុទហេតុបែបនេះហើយ បានជាក្នុង ព-ស-៤៤៣ ឆ្នាំនោះគេឃើញព្រះសង្ឃលង្កាចារធម្មវិន័យនោះជាក់ក្នុងគម្ពីរ តែចារជាសីហលភាសា (ភាសាដែលវិជ័យកុមារជាបុត្រសីហ-ពាហុនាំពីមហាបូរីមកប្រើក្នុងលង្កាទ្វីបគឺភាសាផ្លា-ក្លិង្គ) ៗ

តមកទៀតលោកយល់ឃើញថា : ធម្មវិន័យដែលផ្ទុះជាប់ជាមួយនឹងសីហលភាសានោះ មិនសម្រេចប្រយោជន៍គ្រប់ជាតិសាសន៍បានទេ, ដូចនេះបានជាក្នុង ព-ស ៩៩៦ ពុទ្ធឃោសត្ថុគឺព្រះពុទ្ធឃោសាចារ្យ ទៅប្រែធម្មវិន័យចេញពីសីហលភាសានោះ មកជាមគធភាសា( ភាសាអ្នកមគធៈដែលគេប្រើពីសម័យពុទ្ធកាលគឺភាសាបាលី ) វិញ ៗ

www.budinst.gov.kh www.elibraryofcambodia.org

សួរឆ្ងល់ថា; ចុះកាលធ្វើសង្គាយនារួចថ្មីៗ តាំងពីមុននោះលើក

នោះ ម្ដេចក៏ព្រះសង្ឃគង់ជម្ទប់មិនចារដាក់ក្នុងស្លឹករឹតទៅ ?

ឬក៏សម័យនោះមិនមានអក្សរ ?

ថា ; មិនមែនមិនមានអក្សរនោះទេ ប៉ុន្តែប្រហែលជា

ទុកសមិនទាន់អនុញ្ញាតឲ្យហើយមើល ! បានជាព្រះអរហន្ត

ទាំងឡាយ សុខចិត្តរៀមទុកនូវធម្មវិន័យតែក្នុងមាត់ជាមុខ-

បាឋតៗ គ្នាមកនោះ ។

សុំណាំៈរឿងដែលខ្ញុំសារសាប់មកនេះ គ្រាន់តែជាប្រវត្តិ

មួយសំពប់ទុកជាឯកសារ នៃការប្រជុំបិដកបន្ទាប់បន្សំប៉ុណ្ណោះ,

ប៉ុន្តែៈបើបែរមកសារសាប់អំពីហេតុការណ៍ នៃការប្រែសម្រួល

គម្ពីរអត្ថបទនេះវិញ នោះសាធុជនទាំងឡាយមុខជានឹងឆ្ងល់ខ្លះ

ថា: ចុះអត្ថបទនេះលោកអ្នកសារសេរចាងសង្ខេប ដកប្រែ

ចេញពីគម្ពីរណាមក ?

សូមក្រាបថា : ខ្ញុំអ្នកសរសេរចាងសង្ខេប ត្រឹមតែចង់

www.budinst.gov.kh www.elibraryofcambodia.org

បេះដំនូវខ្លួនឯងប៉ុណ្ណោះ ហើយក៏មានវត្ថុបំណងចង់ឲ្យសាធុជនយល់នូវប្រវត្តិនិងតម្លៃនៃពុទ្ធសាសនាផងដែរ, សោតឯអត្ថបទនេះវិញនោះ ខ្ញុំបានប្រែសង្ខេបអំពីគម្ពីរសមន្តបាសាទិកាអដ្ឋកថាវិន័យព្រមទាំងដីកាត្រង់ពាហិរនិទាន, និងគម្ពីរវិសុទ្ធិមគ្គត្រង់ពុទ្ធឃោសប្បវត្តិ ព្រមទាំងគម្ពីរដទៃខ្លះដែរ, តែភាគច្រើនបំផុតគឺគម្ពីរមហាវង្សខុទ្ទកនិកាយព្រមទាំងដីកា, ទោះជាសេចក្តីយោងក៏ដោយ ។

ឯទីក្បួនបទក្នុងសៀវភៅនេះមានពីរផ្នែកគឺ:

ក–ផ្នែកខាងជម្ពូទ្វីប, ខ–ផ្នែកខាងលង្កាទ្វីប ។

## ផ្នែកខាងជម្ពូទ្វីបមានពីរជំពូកគឺ


១ បឋមសង្គាយនា ទំព័រ ២

២ ទុតិយសង្គាយនា " ៣

៣ – ខត្តិយវង្សក្រុងរាជគ្រឹះក្រោយពុទ្ធបរិនិព្វាន ,, ៧

៤ ប្រវត្តិរបស់ព្រះបាទអសោក ,, ១១

៥ – បុញ្ញានុភាពរបស់ព្រះនាងអសន្ធិមិត្តា ,, ១៦


www.budinst.gov.kh www.elibraryofcambodia.org

៦-សេចក្ដីជ្រះថ្លារបស់ព្រះបាទអសោក " ២២

៧-តតិយសង្គាយនា ,, ២៩

## ផ្នែកខាងលង្កាទ្វីបមាន៦ជំពូកគឺ

១-លង្កាទ្វីបប្បវត្តិនិងពុទ្ធដំណើរ ទំព័រ ៣៤

២-ខត្តិយវង្សក្នុងលង្កាទ្វីប ,, ៣៩

៣ ធាតុនិធាននៃពុទ្ធសាសនារបស់ព្រះគោតម ,, ៤៥

៤-ការចារឹកពុទ្ធវចនៈជាតួអក្សរ ,, ៦១

៥-អ្នកបម្រើពុទ្ធពីលង្កាមកវិញ ,, ៦២

៦-អ្នកបម្រើពុទ្ធនេះបន្តមកទៀត ,, ៦៦

ខ្ញុំយល់ថា: ជំពូកនៃនិទ្ទេសបទទាំងប៉ុន្មាននេះ មុខជាមានហិតប្រយោជន៍ចំពោះពុទ្ធសាសនិកមិនខាន បើមិនច្រើនក៏គង់ជាជំនួយផលស្ពាក់ពីរ. ព្រោះប្រវត្តិនេះជាមាគ៌ាតាមវិជ្ជាខាងពុទ្ធសាសនាស្ទួ ហើយជាគតិមួយសម្រាប់ពន្យល់ខ្លួនឲ្យចេះដឹងនូវការរីកចម្រើននៃពុទ្ធសាសនា ក្នុងដំបន់នៃទ្វីបរបស់

www.budinst.gov.kh www.elibraryofcambodia.org

មនុស្សតាមទេសៈកាលៈផង ។

ចិរដ្ឋតុ សាសនំ ចិរំ

បជាសាយំ សមិជ្ឈតុ

លោកោ សន្តិញ្ច បប្បោតុ

និទ្ទុក្ខា ហោតុ សាបជា ។

សូមឲ្យការប្រព្រឹត្តទៅនៃពុទ្ធសាសនាថិត នៅអស់កាលដ៏យូរ,

សូមឲ្យក៏ប្រាថ្នារបស់មនុស្សលោកនេះ បានសម្រេច ,

សូមឲ្យមនុស្សលោក បានដល់នូវសន្តិសុខ,

សូមឲ្យពួកមនុស្សសត្វចៀសផុតនូវក្តីទុក្ខក្រៀមក្រំ, ។

ព្រះគ្រូឃោសាភិរ័ត

**ហេវត់-ឡាយ**

វត្តមហាមន្ត្រី ភ្នំពេញ.

ថ្ងៃ ៥ ។ ៧ ឆ្នាំម្សាញ់សប្តស័ក ព.ស ២៥០៨
១០

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# បណាមគាថា

សេដ្ឋន្តិលោកគំ ពុទ្ធំ ធម្មំ សំឃំ អនុត្តរំ
វន្ទិយ សាសនស្សេវ បវត្តិញ្ច សមាសតោ
ពុទ្ធកាលា បច្ឆាកាលេ សំខេបេន គាថមិហាន្ទិ

សូមថ្វាយបង្គំចំពោះព្រះពុទ្ធ ជាអគ្គបណ្ឌិតប្រសើរផុតក្នុងត្រៃលោក ព្រមទាំងព្រះធម៌និងព្រះសង្ឃមានគុណឥតគណ៌ជុំមុន, រួចហើយសូមសំដែងនូវប្រវត្តិនៃពុទ្ធសាសនា ក្រោយពុទ្ធកាលដោយសេចក្ដីរួមសង្ខេបដូចតទៅនេះ ។

# ប្រវត្តិពុទ្ធសាសនា

ពាក្យស្ដីប្រដៅរបស់អ្នកប្រាជ្ញម្នាក់ ( ព្រះពុទ្ធ ) ឬពាក្យទូន្មានប្រដៅរបស់អ្នកប្រាជ្ញទាំងឡាយ ( សាវកពុទ្ធ) ហៅថាពុទ្ធសាសនា ,។

ការពង្រីកឬផ្សាយព្រោចទូវធម្មស្ដី របស់អ្នកប្រាជ្ញទាំងនោះទៅក្នុងទិសទីផ្សេងៗ ហៅថាប្រវត្តិពុទ្ធសាសនា ។

ព្រះពុទ្ធនិងសាវកពុទ្ធ ប៉ាន់ស្រាវជ្រាវរួចគ្នាហើយរកឃើញពិត នូវសច្ចធម៌នោះៗ ទើបបញ្ញត្តនិងសំដែង

www.budinst.gov.kh www.elibraryofcambodia.org

ពន្យល់ដល់ពុទ្ធបរិស័ទ ហើយតែងគោរពនូវស្វាក្ខាតធម៌ដែល

ទ្រង់បញ្ញត្តនិងសំដែងហើយនោះមុនគេផង ។

ដូចនេះហើយបានជាពុទ្ធបរិស័ទ លើកយកនូវកិត្តិគុណ

ទាំង៣គឺៈ ព្រះពុទ្ធ១ ព្រះធម៌១ ព្រះសង្ឃ១ មកដំកល់ទុក

ជាត្រៃបារេចនា សំរាប់ជាសក្ខីភាពបូជាគោរពល័ក្ខថាននៃ

ពុទ្ធសាសនា ទុកជាសរណស្ថានតរៀងមក ។

## ប្រវត្តិពុទ្ធសាសនាវិភាគ

ប្រវត្តិពុទ្ធសាសនានេះពាប់បែកតាមទ្វីបមានពីរផ្នែកគឺៈ

១ ផ្នែកខាងជម្ពូទ្វីប, ២ ផ្នែកខាងលង្កាទ្វីប ។

## ក- ប្រវត្តិពុទ្ធសាសនាខាងជម្ពូទ្វីប

### ១- បឋមសង្គាយនា

ប្រវត្តិពុទ្ធសាសនាក្រោយព្រះពុទ្ធនិព្វានហើយនោះ មិន

សូវមានដំណើរពីរប៉ុន្មានជាឯកភាពទេ ចេះតែមានការណ៍រកាំរកូស

រវាងពុទ្ធបរិស័ទមិនស្របយោបល់គ្នាដោយលើកៗ ។

ហេតុនោះបានជាក្នុងពេលព្រះពុទ្ធនិព្វានបាន ៤ ថ្ងៃ គេ

www.budinst.gov.kh www.elibraryofcambodia.org

ឃើញព្រះមហាកស្សបត្ថេរជាប្រធានគណសង្ឃ - ចំនួន៥០០ រូប សន្និបាតក្នុងសត្តបណ្ណគុហា ក្បែរភ្នំវេភារៈដែនមគធៈ ជិតក្រុងរាជគ្រឹះ ប្រជុំគ្នាសើរើនូវវិន័យនិងធម៌មកពោល - ឆ្លើយសូត្រសារជាថ្មីឡើងវិញប្រគេនព្រះសង្ឃស្តាប់ ហៅថាសង្គាយនា លុះចប់ម្តងៗ ព្រះសង្ឃទាំងអស់ដែលគង់ចាំស្តាប់ក៏សូត្រឡើងទាំងអស់ត្រឹមពេលជារបៀបមួយៈហៅថាគានត្រ័យ ។

មកពីសុភទ្ទភិក្ខុមានយោបល់ជំទាស់ចំពោះពុទ្ធសាសនានោះហើយ បានជាព្រះមហាកស្សប ឧបាលី, អានន្ទ ធ្វើបឋមសង្គាយនានេះ ដោយមានព្រះបាទអជាតសត្តុ ជាអ្នកឧបត្ថម្ភផង បឋមសង្គាយនានេះធ្វើពេញ៧ខែទើបចប់ ។

## ២- ទុតិយសង្គាយនា

ក្រោយពីនោះមកអស់រយៈកាលត្រឹមតែ ១០០ ឆ្នាំប៉ុណ្ណោះ អត្ថទោហេតុដ៏ចម្រើនមួយទៀត ក៏បណ្តាលកើតឡើងដោយពួកវជ្ជីបុត្តកភិក្ខុសុំឲ្យកែទ្រង់សិក្ខាបទចំនួន ១០ មាត្រាគឺ

១-សន្និធិការកសិក្ខាបទដែលថា: វត្ថុជាយាវកាលិក ភិក្ខុទទួល

ទុកឲ្យកន្លងរាត្រី ហើយយកមកឆាន់ត្រូវអាបត្តិបាចិត្តិយ
សុំតែថា៖ អំបិលដែលទុកក្នុងកាក់ស្នែង បើទុកជាកន្លងរាត្រី
ក៏ភិក្ខុគួរឆាន់ជាមួយនឹងអាហារបិណ្ឌបាតដែលរកបាន ។ល។

១០- រូបិយសិក្ខាបទ ថែងថា៖ ភិក្ខុមិនត្រូវទទួល ឬ ឲ្យគេ
ទទួលនូវមាសប្រាក់ ត្រេកអរចំពោះមាសប្រាក់ដែលគេទុក
បំរុងឲ្យខ្លួននោះទេ បើទទួល ឬ ត្រេកអរត្រូវអាបត្តិនិស្សគ្គិយ
បាចិត្តិយ. សុំតែថា៖ បើមានដំណើរទៅណេះណោះត្រូវភិក្ខុ
ទទួលកាន់នឹងប្រើប្រាស់បាន ។

រឿងនេះព្រះអរហន្តចំនួន ៧០០ រូប មានព្រះយស-
ត្ថេរកាកណ្ឌកបុត្រ និងព្រះរេវតត្ថេរព្រមទាំងព្រះសព្វកា-
មិត្ថេរជាដើម ឥតយល់ព្រមឲ្យតែទេ ។

ដូចនេះលោកក៏ប្រជុំសង្ឃសន្និបាត សូត្រសារជាថ្មី
ឡើងវិញម្ដងទៀត នូវធម្មវិន័យ ក្នុងកណ្ដាលជំនុំសង្ឃចំនួន
១.២០០.០០០រូប ជាលើកទ២ ហៅថាទុតិយសង្គាយនា ដើម្បី
រម្ងាប់នូវអត្ថុទហេតុនោះ ក្នុងវត្តវាលុការាម ក្រុងវេសាលី រដ្ឋ

www.budinst.gov.kh www.elibraryofcambodia.org

វជ្ជី មានស្តេចកាឡាសោកជាអ្នកឧបត្ថម្ភ ទុតិយសង្គាយនានេះធ្វើ៨ខែទើបចប់ ។

តមកពួកវជ្ជីបុត្តកភិក្ខុ បែកចេញទៅបង្កើតជានិកាយមួយ ហៅថាមហាសំឃិកនិកាយ, ក្រោយមកក្នុង ព.ស ២០០ ពួកមហាសំឃិកនិកាយនេះបែកគ្នាជា៥និកាយគឺ : គោកុលិកា១ ឯកព្យោហារិកា១ បណ្ណត្តិវាទ១ ពហុលិយាវាទ១ ចេតិយវាទ១ (ជា៦ទាំងមហាសំឃិកនិកាយ) ។ មានអាចារ្យវាទពីរ បែកចេញពីថេរវាទគឺ: មហិសាសកា១ វជ្ជីបុត្តកា១ ។ ពួកអាចារ្យវាទនេះបែកគ្នាតទៅទៀតគឺ: ធម្មុត្តរិយា១ ភទ្រយានិកា១ ឆន្នាគារិកា១ សម្មិតិយា១ សព្វត្ថិកា១ ធម្មគុត្តិកា១ កស្សបិកា១ សង្កន្តិកា១ សុត្តវាទ១ (ជា១២ទាំងគណៈជាថេរវាទ) រួមជា១៨និកាយ ។ ពួកនិកាយជាថេរវាទឥតបែកបាក់គ្នាទេ បែកគ្នាតែនិកាយជាមហាសំឃិកនិងជាអាចារ្យវាទនោះ ។ ក្នុង ព-ស ២០០ឆ្នាំនោះ ពួកមហាសំឃិកនិកាយបែកទៅទិសខាងជើង គេហៅថាឧត្តរនិកាយឬមហាយានិកនិកាយ ឯពួក

www.budinst.gov.kh www.elibraryofcambodia.org

និកាយជាថេរវាទបែកមកពីសវាទិន្សូន៍ គេហៅថាភិក្ខុណា-និកាយ ឬហីនយានិកនិកាយ ( និកាយដែលកាន់តាមបែបសង្គាយនាទាំងពីរលើកៈខាះ ហៅថាថេរវាទ ) ។

កាលពុទ្ធសាសនា កំពុងផ្សាយសន្សើរាទៈទាំង ១៨ និកាយនោះ ៗ ក្នុងរវាង ព.ស ២១៤ ទៅ ២១៨ រហូតដល់ ព.ស-២៣៤ ដែលពួកភិក្ខុណានិកាយមកផ្តុំគ្នានៅក្នុងក្រុងប៉ាដលីបុត្រវត្តអសោការាមនោះ មានកើតអធិករណ៍យ៉ាងធំមួយទៀត ហើយសំណុំរឿងព្រមទាំងរឿងតតិយសង្គាយនានេះ នៅក្នុងរជ្ជកាលរបស់អសោកជន៍ ។

មុននឹងនិយាយពីរឿងអធិករណ៍ និងរឿងតតិយសង្គាយ-នានោះ គួរនិយាយពីរឿងខត្តិយវង្សក្រុងធម្មទូបក្រុងពន្ធគ្រឹះនោះជាដើមសិន ព្រោះរឿងនេះមានការទាក់ទងនឹងពុទ្ធសា-សនាជិតស្និទ្ធណាស់ ។

## ៣- ខត្តិយវង្សក្នុងជម្ពូទ្វីបក្រោយពុទ្ធនិព្វាន

១- ព្រះបាទអជាតសត្តុ(១)សម្លាប់បិតាខ្លួនក្នុងឆ្នាំទី ៣៧ នៃពុទ្ធកាល ហើយសោយរាជ្យបាន ៨ ឆ្នាំ ទើបព្រះសម្ពុទ្ធបរិនិព្វាន, ក្រោយព្រះពុទ្ធនិព្វាននោះ អជាតសត្តុសោយរាជ្យបាន ២៤ ឆ្នាំទៀតទើបសុគត ( ព.ស.២៤ ) ។

២- ឧទយភទ្ទ សម្លាប់អជាតសត្តុ ជាបិតាខ្លួនហើយ សោយរាជ្យបាន ១៦ ឆ្នាំ (វេរគ្រោះថ្នាក់បែបនោះទៅក៏បានដល់បុត្រ)

(១) អជាតសត្តុនេះ កាលនៅក្នុងផ្ទៃមាតានោះបណ្ដាលឱ្យព្រះនាងវេទេហី ជាមាតាចង់សោយលោហិតស្វាមី តែមិនហ៊ានប្រាប់ស្វាមីសោះ ទ្រាំទាល់តែស្គមរីងរៃទុកជាព្រះពិម្ពិសារស្ដេចមិនជ្រាប ។ បើព្រះនាងមិនប្រាប់ខ្ញុំជាប្ដី តើព្រះនាងទុកប្រាប់អ្នកណាវិញ?, ថាខ្ញុំម្ចាស់ចង់ ៗ សោយលោហិតស្វាមី ហ៊ះសព្វបើប៉ុណ្ណឹងក៏ចាំណាក់ដែរ។ នោះទ្រង់ឱ្យគេឡាក់ព្រះហស្តស្ដាំយកលោហិតឱ្យសោយ, ពួកហោរាទាយថា កុមារនេះនឹងពិឃាតបិតាឯង ។ ព្រះនាងវេទេហីឮព្រឹត្តិការណ៍នេះ ក៏លបចុះទៅក្នុងឧទ្យានរំលូតគភ៌ចោលតែមិនរលូត, លុះស្វាមីសង្កេតដឹងថា: ព្រះនាងធ្វើបែបនេះនាំឱ្យល្បីពេញជម្ពូទ្វីបហើយ ៗ ក៏ចាត់ឱ្យយាមរក្សា ៗ លុះប្រសូតមកគេយកទារកទៅលាក់ ទាល់តែធំបន្តិចទើបយកមកបង្ហាញព្រះនាងៗ លុះឃើញបុត្រក៏ស្រឡាញ់ឥតធ្វើអ្វីកើត, គេឱ្យនាមថា: អជាតសត្តុ-សត្រូវនឹងបិតាខ្លួនតាំងពីមិនទាន់កើត ។

www.budinst.gov.kh www.elibraryofcambodia.org

(ព.ស.៤០) ។

៣– អនុរុទ្ធ ជាបុត្រ ឧទយភទ្ទ និងមុណ្ឌៈជាបុត្រអនុរុទ្ធ សម្លាប់បិតារៀងខ្លួន ដោយរាជ្យបាន ៨ ឆ្នាំ (ព.ស.៤៨) ។

៤– នាគទស្សកៈ សម្លាប់មុណ្ឌៈជាបិតាហើយ ដោយរាជ្យបាន ២៤ ឆ្នាំ ទើបពួករាស្ត្រក៏សើដន់ធ្វើរដ្ឋប្រហារ សម្លាប់នាគទស្សកៈ និងវង្សស្តេចនេះទាំងអស់ (ព.ស ៧២) ។

៥–កាលផុតពីពូជពង្សពួកស្តេចខាងលើនេះទៅគេរើសយកសុសុនាគកុមារធ្វើស្តេច សុសុនាគ (២) នេះ ដោយរាជ្យបាន ១៨ ឆ្នាំ (ព.ស.៩០) ។

៦– កាឡាសោក ជាបុត្រ សុសុនាគ ដោយរាជ្យបាន ២៨ ឆ្នាំ (ព.ស.១១៨) ។

៧- រាជកុមារ ១០ រូបជាបុត្រ កាឡាសោក ដោយរាជ្យ

---

(២) សុសុនាគនេះ ជាបុត្រស្រីពេស្យាក្រុងវេសាលី បិតាមិនប្រាកដ,កាលកើតមកជាដុំសាច់ មាតាឲ្យយកទៅបោលលើគំនរសំរាម, ពស់នាគមកព័ទ្ធរក្សាក្លាយជាទារក, មនុស្សទៅមើលពស់នាគឲ្យសំឡេងឮសុសុ ហើយរត់បាត់, អមច្ចបុត្រយកទារកនេះមកចិញ្ចឹមឲ្យឈ្មោះថា , សុសុនាគ ។

www.budinst.gov.kh www.elibraryofcambodia.org

បាន ២២ ឆ្នាំ ( ព.ស.១៤០ ) ។

៨– ក្រោយពីពួកស្តេចទាំង ១០ រូបនោះមក មានពួកស្តេចនាមនន្ទា (១) ចំនួន ៩ រូប សោយរាជ្យបាន ២២ ឆ្នាំដែរ (ព.ស ១៦២) ។

៩– ចន្ទគុត្ត(២) សោយរាជ្យបាន២៤ ឆ្នាំ (ព.ស១៨៦)

---

(១)ពួកស្តេចនន្ទានេះជាពួកសូទ្រ,ថាមានពួកចោរមួយក្រុមធំតែងដើរប្លន់អ្នកស្រុក ពេលមួយបានចាប់បុរសម្នាក់កំព្រាឪពុករកស៊ីចិញ្ចឹមម្ដាយ ហើយយកបុរសនេះទៅប្លន់ជាមួយលុះអ្នកស្រុកសម្លាប់មេចោរទៅ ពួកចោរឯទៀតលើកបុរសចិញ្ចឹមម្ដាយនេះធ្វើជាមេចោរ បុរសក្លាហានគឺមេចោរថ្មីនេះថា: យើងត្រូវផ្លាស់ឈ្មោះខ្ញុំថាពួកនន្ទា ៗ, ហើយឈប់រកស៊ីប្លន់អ្នកស្រុកត្រូវប្លន់យករាជសម្បត្តិវិញ ពួកនន្ទាប្រមូលពលបានច្រើនក៏ទៅប្លន់និងដណ្តើមយករាជសម្បត្តិក្រុងបាដលីបុត្រ ដោយសម្លាប់ពួកបុត្រកាឡាសោកទាំងអស់ ហើយឡើងសោយរាជ្យហៅថាពួកស្តេចនន្ទា ។

(២) ចន្ទគុត្តនេះជាវង្សក្សត្រមោរិយៈហើយជាតួធំសាក្យៈផង; ដំណាលថាកាលមោរិយក្សត្រចាញ់សង្គ្រាមនៃស្តេចសាមន្តរាជ; រាជទេវីនៃស្តេចមោរិយៈនេះមានគភ៌ចាស់ខែហើយភៀសខ្លួនទៅប្រសូតបុត្រក្បែរទ្វារក្រោលគោ, នាយគោបាលឈ្មោះចន្ទបានយកកុមាររបស់ព្រះនាងនេះទៅចិញ្ចឹមឱ្យនាមថាចន្ទគុត្ត, ពេលក្រោយចាណក្យព្រាហ្មណ៍ បានសុំកុមារនេះពីចន្ទគោបាលយកទៅឱ្យរៀនសិល្បៈ តមករាជកុមារចន្ទគុត្តនេះប្រមូលពលបានច្រើនទៅច្បាំងដណ្តើមយករាជសម្បត្តិក្រុងបាដលីបុត្រដោយសម្លាប់ពួកស្តេចនន្ទាទាំងអស់ ។

www.budinst.gov.kh www.elibraryofcambodia.org

ស្ដេចនេះកាន់សាសនាព្រាហ្មណ៍ ។

១០— ពិម្ពិសារ(៣) ជាបុត្របន្ធុគ្រ សោយរាជ្យបាន ២៨ ឆ្នាំ (ព.ស.២១៦) ស្ដេចនេះកាន់សាសនាព្រាហ្មណ៍ដែរ ។ ព្រះបាទពិន្ទុសារនេះមានរាជបុត្រចំនួន ១០១ រូប មានអសោកកុមារជាដើម (មាតាអសោកជាស្រីសាក្យាទីនាមនាងសុភទ្រង្គី)។

១១— ចុងវេលាកាលនៃព្រះបាទពិន្ទុសារ គឺកាលព.ស.២១៤ ទើបអសោកជាបុត្រឡើងស្ដេចតមកទៀត ឡើងស្ដេចឥតគេអភិសេកចំនួន៤ ឆ្នាំ, តែបានរាជាភិសេកពេញលក្ខណៈច្បាប់ក្នុងព.ស. ២១៨ ឆ្នាំ ។

## ៤— ប្រវត្តិរបស់អសោក

អសោកកាលពីកម្លោះ ព្រះបាទពិន្ទុសារជាបិតា បញ្ជូន

(៣) កាលពិន្ទុសារនេះនៅក្នុងផ្ទៃមាតានៅឡើយហនុកព្រាហ្មណ៍ជាបុរោហិតបានផ្សំថ្នាំពិសដាក់ក្នុងនំ ថ្វាយស្ដេចបន្ធុគ្រទុកការពារសត្រូវ, ស្ដេចនេះហុចទៅឲ្យអគ្គមហេសីទុក ឯព្រះនាងមិនដឹងក៏យកនំនេះសោយ ហនុកព្រាហ្មណ៍ក្រឡេកឃើញទាន់ ក៏យកដាវកាត់កព្រះនាងការពារកុំឲ្យស្លាប់ទារក ភ្លាមនោះគេវះយកទារកទាំងស្រោមទៅបញ្ចូលក្នុងពោះមេពពែហើយដេរភ្ជិតភ្លាម, ៧ថ្ងៃទើបប្រសូតហើយ មានលោហិតស្រក់តក់ៗពីសរីរៈទារក, ហេតុនោះគេឲ្យនាមថា:ពិន្ទុសារ ។

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យទៅនៅក្រុងឧជ្ជេនី រដ្ឋអវន្តិ, នាពាយ័ព្យទិសក្រុងបាដលិ-បុត្រ ធ្វើជាឧបរាជគ្រងរដ្ឋនោះ ។

លុះធ្វើដំណើរទៅដល់ទីក្រុងតូចមួយ ហៅថាវេទិសនគរ នាកណ្ដាលផ្លូវនោះ ក៏ចូលទៅសម្រាកក្នុងផ្ទះសេដ្ឋីម្នាក់ឈ្មោះ វេទិស: បានឃើញសេដ្ឋីធីតានាមនាងវេទិសា មានរូបសម្បត្តិ និងលក្ខណសម្បត្តិដ៏ប្រិមប្រិយ ជាបុត្រីរបស់សេដ្ឋីនោះ ក៏បានដណ្ដឹងរៀបអាពាហ៍ពិពាហ៍ រួចនៅទីនោះ លុះនាងមានគភ៌ ទើបនាំប្ដីទៅនៅឯក្រុងឧជ្ជេនីឯណោះ ។

អសោកនិងអគ្គជាយានេះ មានបុត្រមួយនាមមហិន្ទកុមារ ពីរឆ្នាំកន្លងមកបានបុត្រីម្នាក់ទៀតនាមនាងសង្ឃមិត្តា ។

ពេលដែលកុមារ និងកុមារី មានអាយុកំពុងតែរត់លេង នោះ ក៏ស្រាប់តែអសោកបានទទួលព្រះរាជសារអំពីរាជទូតម្នាក់ថា : ព្រះបិតាមានអាពាធធ្ងន់ណាស់ ! ។

ពត៌មានដ៏អាណោចអធ័មនេះ ធ្វើឲ្យអសោកញ័ររន្ធត់យ៉ាងខ្លាំង ណាមួយអាណិតកូនប្រពន្ធ ណាមួយបិតាមានអាពាធ

www.budinst.gov.kh www.elibraryofcambodia.org

ប៉ុន្តែទុគាសគ្មានអនុញ្ញាតឲ្យអសោកបង្អែបង្អង់បានឡើយ ដូច្នេះ អសោកត្រូវកាត់ចិត្តនាំប្រពន្ធកូនមកទុកឯក្រុងវេទិសនគរ ជាស្រុកកំណើតភរិយា, ទុកជាប្រពន្ធកូនអង្វរគេសុំទៅជាមួយយ៉ាងណាក៏មិនបាន ព្រោះមាគ៌ាឆ្ងាយណាស់ ហើយការនេះជាប់ទាន់ផង ។

ពេលដែលប្រពន្ធកូនកំពុងឈរយំ តាមមើលដំណើរប្ដីនឹងឪពុក, នោះអសោកបំផាយអស្សតរយ៉ាងលឿន ដោយងាកមើលប្រពន្ធកូនសម្រក់ជលនេត្រលើខ្នងអស្សតរម្ដង ៗ ។

លុះទៅដល់ក្រុងបាដលីបុត្រ បិតាក៏សុគតផុតភ្លាម, អវសាននៃឈាបនកិច្ចសពនេះរួច អសោកក៏ចាត់ការយករាជ-សម្បត្តិ តែព្រះអនុជទាំងអស់ដែលមានមាតាផ្សេងពីអសោកមិនយល់ព្រមឲ្យរាជសម្បត្តិទៅអសោកឡើយ រឿងនេះកើតជាចម្បាំងយ៉ាងធំ តែទីបំផុតជ័យជំនះបានមកអសោក ដោយអសោកសម្លាប់ប្អូន ៗ ចោលទាំងអស់ ទុកតែតិស្សកុមារម្នាក់ដែលរួមមាតាជាមួយនឹងខ្លួន ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ អសោកធ្វើស្តេចឥតគេអភិសេកចំនួន ៤ ឆ្នាំ លុះក្នុងព.ស.២១៨ ទើបគេធ្វើរាជាភិសេកអសោកពេញច្បាប់ ជាមួយនិងព្រះនាង អសន្ធមិត្តា ដែលជាស្ត្រីមានបុញ្ញាភិនិហារ និងលក្ខណសម្បត្តិឯកមួយ ឲ្យសោយរាជ្យក្នុងក្រុងបាដលិបុត្រ. អសោកមានអំណាចឥតគណនា បានផ្សាយអាណាចក្ររបស់ខ្លួនពេញជម្ពូទ្វីបទាំងមូល ។

បុណ្យានុភាពរបស់អសោកនេះ មិនត្រឹមតែផ្សាយព្រោចទៅលើមនុស្សក្នុងជម្ពូទ្វីបប៉ុណ្ណោះទេ តែគង់ផ្សាយព្រោចទៅលើអាកាសនភាល័យ និងក្រោមដីចំនួន១យោជន៍ផងដែរ. ហេតុនោះបានជាគេឃើញពួកទេវតានាំដង្វាយមកថ្វាយរាល់ទិវារាត្រី ដូចជាទឹកអនោតត្តស្រះ, ឈើស្ទន់, ថ្នាំកែរោគ, ផ្លែស្វាយទុំ, សំពត់ស្បៀកពាក់, កន្សែងសម្រាប់ជូតដៃ. និងទឹកអប់ទិព្វជាដើម ,

ឯពួកស្តេចនាគក៏នាំដង្វាយមកថ្វាយរាល់ទិវាកាលដែរ

www.budinst.gov.kh www.elibraryofcambodia.org

ដូចជាគ្រឿងក្រអូបសម្រាប់កក់ក្បាល; សម្រាប់លាប; សំពត់ទិព្វមិនមែនអម្បោះ កម្រងផ្កាម្លិះ,ទឹកថ្នាំបន្តក់ភ្នែកជាដើម ។

ឯសត្វសេកទាំងហ្វូង ៗ ក៏នាំស្រូវសាលីទាំងរវេះ ៗ ពីឆទ្ទន្តស្រះមកទំលាក់ថ្វាយរាល់ថ្ងៃដែរ ។

ឯសត្វកណ្តុរជាអ្នកធ្វើអង្ករមិនឲ្យមានកន្ទក់ថ្វាយរាល់ថ្ងៃដែរ ៗ សត្វឃ្មុំក៏មកធ្វើសម្បុកក្បែរៗព្រះរាជនិវេសន៍ ទីទីនានា, ឯសត្វខ្លាឃ្មុំជាអ្នកឡើងដើមឈើយកឃ្មុំនោះមកថ្វាយអសោក ។

ឯសត្វការវិកបបួលគ្នាហើរព្រោចពាសពេញ រាជនិវេសន៍ប្រគំសូរបទនឹងសំនៀងពិរោះរបស់គេ ថ្វាយអសោករាល់ទិវារាត្រី ។

វត្ថុដែលគេនាំថ្វាយទាំងប៉ុន្មាន អសោកតែងប្រគេនដល់ព្រះសង្ឃចំនួន ៨ ភាគ ១០, ទឹងប្រគេន ២ ភាគ ១០ ដល់ព្រះសង្ឃដែលចេះចាំនូវបិដកទាំង៣ចំនួន៦០អង្គ, ពេលណាដែលលោកជ្រះថ្លាក្នុងពុទ្ធសាសនាហើយនោះ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្រោយពីនោះ ទ្រង់ប្រទានដល់អគ្គមហេសីនាម អសន្ធិមិត្តា ចំទួនពីគោត, ហើយសម្រាប់ស្រីៈបុាំទិនខ្លួនៈលាកពីគោតដែរ ។

តែអសោកដូចជាភ្លេចអគ្គជាយាកំសត់ ទិនបុត្រពីររូប ទៅក្រុងវេទិសៈ ដែលគ្នាកំពុងយំសោកៈធំចាំម៉ែលខ្លួន ទិនទន្ទឹងចាំពាក្យសន្យារបស់ខ្លួននោះ ។

ឱ នារីទិនបុត្រកំព្រា ! ពេលអសោកចេញទៅលផុតមក នាងនិងបុត្រពីររូប តែងទន្ទឹងខ្សឹកខ្សួលនឹកស្វាមីជានិច្ច ថ្ងៃមួយលុះចាំស្វាមីបាត់ដំណឹងយូរពេកក៏ដាច់ចិត្តនាំបុត្រនាំទិនពីរមកអង្គុយសញ្ជប់សញ្ជឹង ចាំស្តាប់តែពត៌មាន ។

ថា : ពេលដែលគេរៀបរាជាភិសេកអសោកពេញច្បាប់នោះ មហិន្ទកុមារមានអាយុ១៤ឆ្នាំហើយ ឯនាងសង្ឃមិត្តាមានអាយុ១២ឆ្នាំហើយដែរ. តែមាតារបស់កុមារ កុមារិកានេះមិនព្រមនាំបុត្រទៅជួបអសោកឡើយ ប្រហែលជានាងដឹងថាអសោកមានអគ្គមហេសីថ្មីទៀតនោះហើយមើល៍ ? ។

ប៉ុន្តែពេលរាជាភិសេកអសោកពេញច្បាប់នោះ បុត្រ

www.budinst.gov.kh www.elibraryofcambodia.org

ទាំងពីរនេះ ដោយចង់ឃើញមុខបិតាគេ ក៏យំអុកម្ដាយពន់ពេក មាតាក៏ឲ្យគេនាំបុត្រទាំងពីរនេះទៅ ហើយផ្ដាំថា: បើមានការសុខ-ទុក្ខក៏ឆាប់វិលមកវិញ ទីងឆាប់ឲ្យពតិមានមកម្ដាយវិញណាកូន ! ។

បុត្រទាំងពីរនេះបានជួបបិតាគេដោយសុវត្ថិភាព អសោកស្រឡាញ់បុត្រទាំងពីរនេះដូចដាបណ្ដូលចិត្ត ទាំងព្រះនាងអសន្ធិមិត្តា ក៏ស្រឡាញ់បុត្រទាំងពីរនេះដូចបុត្របង្កើតរបស់ព្រះនាង ។

## ៥. បុញ្ញានុភាពរបស់ព្រះនាងអសន្ធិមិត្តា

ព្រះនាងអសន្ធិមិត្តានេះ មានរូបសម្បត្តិល្អមិនមានស្នាមដំណាំគឺល្អមិនពាស់ស្នាក់ហើយជាពុទ្ធមាមកា មានសទ្ធាបំផុតក្នុងពុទ្ធសាសនា, ថ្ងៃមួយអសោក និងព្រះនាងបាននិមន្តព្រះសង្ឃចំនួន ៦១.០០០ អង្គឆាន់ ព្រះលោកឆាន់រួចហើយអសោកនិងព្រះនាងក៏យាងទៅដំណាក់រៀងខ្លួន ។

ដើមរាត្រីនោះអសោកបានចូលទៅបន្ទប់ព្រះនាង ដែល

www.budinst.gov.kh www.elibraryofcambodia.org

កំពុងតែសោយទឹកអំពៅ អសោកបានចំអន់លេងថាៈ ព្រះនាងមានភ័ត្រល្អណាស់គង់លើរទេះញ្ញូនតៅអី សោយទឹកអំពៅធ្ងើនគ្រោតូចធំៗ ប្រហែលជាឆ្ងាញ់ណាស់ហើយមើល ?

ដោយមានអ្នកគាបអំពៅនៅក្បែរនោះផង ព្រះនាងអសន្ធិមិត្តាក៏នឹកអៀនតូចព្រះទ័យនឹងពាក្យចំអន់នោះ, ទើបព្រះនាងបេ្ហូតបាត់ថាៈ ខ្ញុំម្ចាស់សោយតែទឹកអំពៅដែលគេគាបនាំមកថ្វាយខ្ញុំទេតើ ? ដោយអំពៅនោះកើតដោយសារបុណ្យខ្ញុំម្ចាស់ ! ។

អសោកឮល៏ក៏តបទោសថាៈ ឥស្សរិយយសទាំងអស់ក្ដី សម្បត្តិទ្រព្យទាំងអស់នេះក្ដី ក៏សុទ្ធតែកើតដោយសារបុណ្យនាងទាំងអស់ហើយ នាងនិយាយនេះបង្អាប់កិត្តិយសខ្ញុំហួសពេក ទុកខ្ញុំដូចមនុស្សទរកៈទាំហើយ, តែណ្ហើយចុះស្អែកនេះយើងនិមន្តព្រះសង្ឃ ៦០.០០០ មកឆាន់ទៀត ហើយនាងរកត្រៃចីវរ ៦០.០០០ ត្រៃមកប្រគេនលោកឲ្យបាន ឲ្យខ្ញុំបានដឹងបុណ្យរបស់នាងផង ។



www.budinst.gov.kh www.elibraryofcambodia.org

បើនាងរកមិនបានទេ នោះនាងត្រូវទទួលទណ្ឌកម្មធ្ងន់បំផុត អ្នកសោកជាតែប៉ុណ្ណោះក៏បយចេញទៅបាត់ ។

ក្រោយនោះព្រះនាងអសន្ធមិត្តាទ្រង់កន្ទ្រងសោយសោកទឹកមុខស្រពោនដូចផ្កា នាងដកដង្ហើមធំហើយអង្គុយទៅតែកន្ទ្រង់ថា: ឱស្វាមីអើយ ! មិនគួរទ្បាល់បាប់កំហុសខ្ញុំសោះ! ឲ្យខ្ញុំទៅរកត្រៃចីវរឯណាទាំងពត្រះខេះបាន ? ព្រះនាងព្រួយណាស់ដើរចុះ-ឡើង ផ្ទុំក៏មិនលក់ហើយស្ទុះក្រោកទៅយំសម្រក់ទឹកនេត្រលើមុខបុត្រនាងបន្តិច រួចលើមកអង្គុយបន្តិច សោបសល់តតលក់សោះនាពត្រីនោះ ។

ពេលនោះស្តេចទេវតាទាំង ៤ បញ្ជាឲ្យស្តេចកុវេរវេស្សវណ្ណ យកប្រអប់សំឡទិព្វមកថ្វាយព្រះនាង, ស្តេចនេះលុះទៅដល់នាងហើយក៏ថា: ព្រះនាងកុំសោកបារម្ភអ្វី ប្រអប់នេះជារបស់ទិព្វ នាងប្រាថ្នាអ្វីបានទាំងអស់ រួចក៏លានាងបាត់ទៅ ។

លុះព្រឹកឡើងព្រះសង្ឃចំនួន ៦០.០០០អង្គមកដាន់លោក

www.budinst.gov.kh www.elibraryofcambodia.org

ភិក្ខុរូបអសោកថា: ចូរព្រះនាងយកត្រៃចីវរមកប្រគេនលោក !

ព្រះនាងក៏ថ្វាយប្រអប់ទិព្វនោះភ្លាម ស្រាប់តែត្រៃចីវរចេញ

ពីប្រអប់នោះមកទាំងត្រៃៗបានគ្រប់ព្រះសង្ឃទាំងអស់, អសោក

វេបស្រឡាំងកាំងមិនចេញស្ដីអ៊ីសោះ រួចហើយក៏ក្រោកទៅ

ដំណាក់រៀងខ្លួន ។

បន្ទាប់នោះ អសោកបញ្ជាឲ្យគេយាងព្រះនាងអសន្ធិមិត្តា

មក ក្នុងកណ្ដាលចំណោមមុខមន្ត្រី អសោកនិយាយលន់តួថា:

សូមព្រះនាងអត់ទោសដល់ខ្ញុំផង ហើយដោះសារថាខ្ញុំបង់ជីវិត

បុណ្យនាងទេតើ !

ព្រះនាង .., ខ្ញុំម្ចាស់ឥតយកទោសស្វាមីទេ ស្វាមីទេ

តើយកកំហុសខ្ញុំម្ចាស់ ! ។

អសោក ... ខ្ញុំជីវិតបុណ្យព្រះនាងហើយ ពីពេលនេះទៅ

មុខ ឥស្សរិយភាពទាំងអស់ព្រមទាំងស្ត្រីប្រាំចំនួន ១៦.០០០រូប

ក្នុងបុរីនេះ ខ្ញុំសូមប្រគល់ថ្វាយនាងជាដាច់ខាត ។

ពួកស្ត្រីទាំងនោះបបួលគ្នានិន្ទាអសោក, អសោកចាត់

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យនាយពិសេសបំអិនន់ចំនួន ១៦.០០៦ ហើយបង្កប់ព្រះទម្រង់មួយវង់កាត់ថ្ងៃមិនបានកន្លះមួយ ឲ្យស្ត្រីបុាំពាន់ ១៦.០០០ រូប ទាំងព្រះនាងអសន្ធិមិត្តាផង រើសយកនំមួយម្នាក់ៗ ឯព្រះនាងអសន្ធិមិត្តាបានរើសយកនំក្រោយគេបំផុត រួចហើយទ្រង់ឲ្យបកនំនោះមើល នំដែលបង្កប់ព្រះទម្រង់នោះ; បានលើព្រះនាងអសន្ធិមិត្តា អសោកថា: នាងពល់គ្នាឃើញឬទេ គឺនាងពល់គ្នាជាស្ត្រីឥតបុណ្យ ឯព្រះនាងអសន្ធិមិត្តាទើបជាស្ត្រីមានបុណ្យឯក ដូច្នេះនាងពល់គ្នាឈប់ប្រណែនបុស្បាទៅ ៗ ព្រះនាងអសន្ធិមិត្តាទាញសំពត់ពីប្រអប់ទិព្វ ១.០០០ ក៏ថ្វាយស្វាមី, និងទ្រង់ប្រទានដល់ឧបរាជ-មុខមន្ត្រីនិងយុវនារីនោះៗ ចំនួន ៥០០ ក៏ក្នុងម្នាក់ៗផងដែរ, ហើយប្រទានដល់ពលរេហ៍និងជនសាមញ្ញចំនួន ៥០ ក៏ក្នុងម្នាក់ ១ ៗ

អសោករន្ធត់ចិត្តព្រឺខ្លួនញាក់ៗក៏សួរថា: ព្រះនាងបានវត្ថុពិសេសទិព្វនេះពីណាមក ?

បពិត្រស្វាមី ! ប្រអប់ទិព្វនេះស្តេចទេវតានាមកុវេរៈឲ្យខ្ញុំ

www.budinst.gov.kh www.elibraryofcambodia.org

ៈទឹកតែហើយ ស្ការបុណ្យដែលខ្ញុំម្ចាស់បានប្រគេនក្រមាមួយ ជាចីវរដល់ព្រះបច្ចេកពុទ្ធអតីតកាល ។

បពិត្រស្វាមី! បើខ្ញុំម្ចាស់ចង់ឲ្យនូវសេពគប់ឲ្យនូវវត្ថុអ្វីមួយ ឬក៏ខ្ញុំប្រាថ្នានូវអ្វី ១ ក៏បានសម្រេចដោយប្រអប់បុណ្យនេះដែរ ។

បពិត្រស្វាមី! សូមស្វាមីខិតខំរៀនធម៌, សូមស្វាមីធ្វើបុណ្យកុសលឲ្យញយៗ; សូមស្វាមីរក្សាសីលកុំឲ្យដាច់, សូមស្វាមីទូន្មានចិត្តឲ្យល្អកុំគ្រេវក្រោធឥតសមហេតុ-ផល, សូមស្វាមីសេពគប់តែកល្យាណមិត្រ, សូមស្វាមីកុំបណ្ដែតបណ្ដោយឲ្យលង់ស្មារតី សូមស្វាមីប្រព្រឹត្តធម៌ សូមស្វាមីរក្សាក្រឹត្យតាមសមធម៌ សូមស្វាមីកុំប្រើអំណាចទៅលើមនុស្សដែលទន់ទាបជាងខ្លួន ធ្វើបែបនេះទើបស្វាមីបាននូវផលល្អ; (សំដីពាក្យនេះមានន័យថា មុខជាប់តទៅនៅភពណាមុខទៀតក៏បានទៅកើតសុគត) ។

www.budinst.gov.kh www.elibraryofcambodia.org

## ៦- សេចក្តីជ្រះថ្លារបស់អសោក

ថា:អសោកធ្លាប់បានឃើញរូបពុទ្ធនិម្មិត ដែលកាឡនាគរាជនិម្មិតថ្វាយកើតបីតិសោមនស្ស ទើបទ្រង់ឈរបូជាមិនប៉ព្រិចព្រះនេត្រ មិនបរិភោគអាហារចំនួន ៧ ថ្ងៃទតពុទ្ធនិម្មិតនោះ ។

ថា.អសោករាជាភិសេកបាន ៣ ឆ្នាំ នោះនៅប្រកាន់តាមលទ្ធិព្រាហ្មណ៍ ដែលជាគតិបិតាលោកនៅឡើយ, លុះរាជាភិសេកបាន ៤ ឆ្នាំ ទើបជ្រះថ្លាស៊ប់ក្នុងពុទ្ធសាសនា គឺដោយសារតែទ្រង់បានឃើញ និងបានស្តាប់នូវធម្មទេសនារបស់អរហន្តមួយរូបនាមនិគ្រោធ(១)សាមណេរជាក្មួយនោះឯង ។

---

(១) កាលអសោកសម្លាប់បិតារបស់សាមណេរនេះ ៗ នៅក្នុងឧទរមាតានៅឡើយ សុមនាទេវីជាមាតាសាមណេរនេះ ភ័យខ្លាចអសោកសម្លាប់នាងទៀត ក៏ភៀសខ្លួនដើរកាត់ព្រៃ ហើយក៏ប្រសូតបុត្រក្រោមដើមជ្រៃលើវេទិកាល្អមួយដែលទេវតានិម្មិតថ្វាយ; អ្នកស្រុកចណ្ឌាលជួយទំនុកបំរុងនាងនិងទារកនេះៗ នាងឲ្យនាមថា និគ្រោធកុមារ លុះកុមារនេះមានអាយុ ៧ ឆ្នាំ មហាវរុណត្ថេរសុំយកទៅបំបួសជាសាមណេរ បានសម្រេចព្រះអរហត្ត ថ្ងៃមួយលោកនេននេះនិមន្តកាត់មុខវាំងទៅប្រោសញោមស្រីលោក អសោកឃើញក៏ស្រឡាញ់-ជ្រះថ្លាចំពោះឥរិយាបថលោកនេននេះ ទើបនិមន្តចូលវាំងឲ្យសំដែងធម៌ ។

www.budinst.gov.kh www.elibraryofcambodia.org

ថា: អសោកមានសទ្ធាមិនញាប់ញ័រ ទ្រង់ឋិតក្នុងសីល៥ ជានិច្ច, ហើយឧបត្ថម្ភព្រះសង្ឃនិងឲ្យកសាងវត្តចំនួន៨៤០០០ មានអសោការាមជាដើមសម្រាប់ព្រះសង្ឃនៅ. និងឲ្យកសាងព្រះចេតិយចំនួន ៨៤០០០ គ្រប់នគរទាំង ៨៤០០០ នគរក្នុងជម្ពូទ្វីបដែលជាអាណាចក្ររបស់ខ្លួន ។

ចំនួននេះទុកជាសក្ខីភាព បូជាចំពោះព្រះធម៌របស់ព្រះពុទ្ធចំនួន ៨៤០០០ ធម្មក្ខន្ធនោះ ។ ការកសាងនេះចំនួន៣ ឆ្នាំទើបហើយ ។ (ថា: អសោកបានឲ្យប្រមូលព្រះសារីរិកធាតុទាំងអស់របស់ព្រះសម្ពុទ្ធ ក្នុងជម្ពូទ្វីប មកបញ្ចុះក្នុងព្រះចេតិយថ្មីនេះ ហើយឲ្យសាងសិលាចារឹកគ្រប់សំវេជនីយដ្ឋាន និងពោធគយាផង) ។

ថា: ក្នុងថ្ងៃធ្វើបុណ្យឆ្លងសមិទ្ធចំនួន ៧ ថ្ងៃយប់នោះ អសោកព្រមទាំងពលរេហ៍ទាំងអស់ បានយាង.អញ្ជើញទៅវត្ត ហើយគង់កណ្តាលព្រះភិក្ខុសង្ឃ សុទ្ធតែសមាទានសីល៨ទាំងអស់គ្នា ។

www.budinst.gov.kh www.elibraryofcambodia.org

ថា: ក្នុងមហាសន្និបាតនោះ មានភិក្ខុសង្ឃចំនួន៨០កោដិ ភិក្ខុនីសង្ឃចំនួន ៩៦ សែនរូប ។ ក្នុងចំនួននោះមានភិក្ខុ-ភិក្ខុនី ជាព្រះអរហន្តចំនួន ១០០.០០០ អង្គ ។

ដោយបំណងឲ្យអសោកព្រះបាទជាភិរម្យភាពទៀត នោះព្រះអរហន្តទាំងឡាយបានសំដែងបាដិហារ្យ ឲ្យអសោកទតឃើញជម្ពូទ្វីប ឃើញទាំងអស់ទល់នឹងមាត់សមុទ្រ ។ ថា: ពេលធ្វើបុណ្យសម្ពោធនេះ មនុស្សទៅតែមើលគ្នាឃើញទាំងអស់ ។

(ថា អសោកដោយជ្រះថ្លាខ្លាំង បានបួសចំនួនពីរសេព្វ)។

ថា: អសោកសួរព្រះភិក្ខុសង្ឃថា ក្នុងពុទ្ធសាសនានេះ មានជនណាបរិច្ចាគធំជាងបុណ្យនេះឬទេ ?

ព្រះមោគ្គលីបុត្តតិស្សត្ថេរថា: សូម្បីប្រោបទុកជាកាលព្រះពុទ្ធគង់នៅក៏មិនមានជនណាបរិច្ចាគធំយ៉ាងនេះឡើយ ។

អសោករឹតតែរីករាយជ្រះថ្លាជាអនេកប្បការទៀត, ដូច្នេះ ខ្ញុំព្រះករុណាបាននាមថា ជាសាសនទាយាទ គឺជាសាច់ញាតិនឹងពុទ្ធសាសនាហើយឬ ? ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះមោគ្គលីបុត្ត...លុះតែទ្រង់ឲ្យបុត្រធីតាបួសទៀត ទើបបានព្រះនាមថាជាសាសនទាយាទក្នុងពុទ្ធសាសនា ។

ពេលនោះមហិន្ទកុមារមានអាយុ ២០ ឆ្នាំគត់ ឯនាងសង្ឃមិត្តាមានអាយុ ១៨ ឆ្នាំ ហើយនាងមានបុត្រមួយឈ្មោះសុមនកុមារទៀតផង,... តែតាំងពីស្វាមីនាងឈ្មោះអគ្គិព្រហ្ម (ក្មួយអសោក) បួសជាមួយនឹងតិស្សឧបរាជ ដែលជាប្អូនរបស់អសោកនោះទៅ, ព្រះនាងក៏នៅមេម៉ាយ ឯនាទីឧបរាជក៏នៅទំនេរ ដូច្នេះ នាទីឧបរាជនេះអសោកប្រុងឲ្យទៅមហិន្ទកុមារជាបុត្រ ។

ប៉ុន្តែលុះទ្រង់ព្រះថេរដីកាដូច្នោះ ក៏ទ្រង់បែរមកពិភាក្សានឹងបុត្រទាំងពីរនោះ ឯបុត្រធីតាទាំងពីរក៏ព្រមបួសដោយសេចក្តីសោមនស្ស ។

គ្រានោះគេឃើញព្រះមោគ្គលីបុត្តតិស្សត្ថេរ ជាឧបជ្ឈាយ៍ ព្រះមហាទេវត្ថេរជាកម្មវាចា ព្រះមជ្ឈន្តិកត្ថេរជាអនុស្សាវនៃបំបួសមហិន្ទកុមារនោះ ។ បួសហើយមិនយូរប៉ុន្មានក៏បាន

www.budinst.gov.kh www.elibraryofcambodia.org

សម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា ។

ឯនាងសង្ឃមិត្តា គេឃើញអាយុបាលគ្រប់ជាអាចារ្យ ធម្មបាលត្រូវជាឧបជ្ឈាយ៍ បំបួសជាសាមណេរី ហើយឲ្យសិក្សានូវសិក្ខាបទ៦មានបាណាតិបាតាជាអាទិ៍ អស់រយៈកាលពីរឆ្នាំ ទើបបំបួសជាភិក្ខុនី តមកក៏បានសម្រេចព្រះអរហត្ត ដែរ ។

ថា: កាលបុត្រទាំងពីរនេះបួស អសោករាជាភិសេកបាន ៦ឆ្នាំហើយ (ព-ស-២២៤) មហិន្ទត្ថេរបួសបាន៣ឆ្នាំ ទើបរៀនចប់នូវបិដកទាំង៣ព្រមទាំងអដ្ឋកថាព្រមទាំងថេរវាទ ហើយបានជាប្រធាននៃសិស្សចំនួន១០០០រូប នោះអសោករាជាភិសេកបាន៩ឆ្នាំ (ព-ស-២២៧) ។

តពីនោះមក អសោកតែងចំណាយព្រះរាជទ្រព្យចំនួន ៥០០.០០០កហាបណៈរាល់ៗថ្ងៃ គឺ១០០ ០០០សំរាប់និគ្រោធត្ថេរជាគម្ពីរ , ១០០.០០០ សំរាប់ពុទ្ធបូជា, ១០០.០០០ សំរាប់ធម្មបូជា, ១០០.០០០ សំរាប់សង្ឃបូជា, ១០០.០០០

www.budinst.gov.kh www.elibraryofcambodia.org

សំរាប់មន្ទីរពេទ្យនិងថ្នាំសង្កូវ ចែកកូនស្រូវ ទូរទាំង ៤ទិស ។

(ថាៈ អសោកមានតែផ្លែស្រមរនិងកន្ទួតព្រៃមួយក៏ធ្វើជាវត្ថុប្រគេនសង្ឃដែរ)។

ពេលនោះលាភសក្ការៈ កើតចំពោះពុទ្ធសាសនាច្រើនជាអនេកអនន្ត, នាំឲ្យពួកនិគ្រន្ថតិរ្ថិយ ចូលមកបន្លំបួសបួមដើម្បីលាភនោះ, ថែមទាំងពោលបំភ្លាត់ធម្មវិន័យ បង្កចលនាអធិករណ៍ ពាសពេញកូនវត្តអារាមឥតអ្នកណារម្ងាប់បាន, ឯភិក្ខុសង្ឃបរិសុទ្ធក៏ឈប់ធ្វើសង្ឃកម្មទាំងអស់ជាមួយនិងពួកនោះ ។

ព្រះមោគ្គល្លីបុត្តតិស្សត្ថេរ កាលមិនអាចរម្ងាប់អធិករណ៍នេះបាន លោកក៏ប្រគល់ការសង្ឃឲ្យមហិន្ទត្ថេរគ្រប់គ្រង ខ្លួនលោកក៏ភៀសទៅនៅឯភ្នំអហោគង្គាឯណោះ ។

កូនអសោការាមទាំងមូល លែងមានឧបោសថអស់រយៈកាលចំនួន ៧ ឆ្នាំ (អសោករាជាភិសេកបាន ១៦ ឆ្នាំ មហិន្ទត្ថេរបួសបាន ១០ វស្សាហើយ (ព-ស-២៣៤) ។

www.budinst.gov.kh www.elibraryofcambodia.org

គ្រានោះអសោកធម្មរាជ បញ្ជាឲ្យសេនាមាត្យទៅជួយរម្ងាប់អធិករណ៍នេះ តែអាមាត្យល្ងង់ខ្លោះបែរជាសម្លាប់ពួកភិក្ខុអស់ជាច្រើន ។

រឿងឃាតកម្មនេះនាំឲ្យអសោកក៏រន្ធត់យ៉ាងខ្លាំង ទើបទ្រង់ចាត់រាជទូតនិងសេនាមាត្យជាច្រើនលើក ឲ្យទៅនិមន្តព្រះមោគ្គលីបុត្តតិស្សត្ថេរមកវិញ ។

លុះព្រះមោគ្គលីបុត្តមកដល់ បានពន្យល់នូវហេតុការណ៍ផ្សេងៗ នៃលទ្ធិពុទ្ធសាសនាចំនួន៧ថ្ងៃថ្វាយឲ្យអសោកយល់, ថ្ងៃទី៧នោះអសោកបញ្ជាឲ្យបិទបាំងកាំងនជាសង្កាត់ៗ ហើយឲ្យសង្ឃទាំងអស់ក្នុងអសោការាម អង្គុយជុំគ្នាដោយពួកៗតាមលទ្ធិរៀងៗខ្លួនក្នុងសង្កាត់នោះៗ រួចទើបទ្រង់សួរមួយពួកម្ដងៗ ថា :

ព្រះសម្ពុទ្ធទ្រង់ពោលអ្វី ?

ក្រុមនីមួយៗសុទ្ធតែពោលតាមលទ្ធិមិនចំផ្លូវ ខុសពីពុទ្ធសាសនា, នោះទ្រង់ឲ្យផ្សឹកចេញទាំងអស់ ចំនួន៦០០០០រូប,

www.budinst.gov.kh www.elibraryofcambodia.org

ទុកតែក្រុមណាដែលឆ្លើយថា : ព្រះសម្ពុទ្ធទ្រង់ពោលអាត់កម្មផល ។

រួចហើយព្រះសង្ឃទាំងឡាយ ក៏បបួលគ្នាធ្វើសាមគ្គីឧបោសថក្នុងអាវាសនោះ ។

## ៧- តតិយសង្គាយនា

កាលព្រះមោគ្គលីបុត្តតិស្សត្ថេរ បានរម្ងាប់នូវបរប្បវាទគឺលទ្ធិពួកនិគ្រណ្ឋតិរ្ថិយរួចហើយ ដោយមានលោកជាប្រធាន ក៏បានរើសព្រះអរហន្តបដិសម្ភិទា និងវិជ្ជា៣ ចំនួន១.០០០រូប មានមហិន្ទត្ថេរជាដើម ពីក្នុងចំណោមភិក្ខុ៦០សែនអង្គនោះមក ប្រជុំគ្នាក្នុងវត្តអសោការាម ជិតក្រុងបាដលិបុត្រ ធ្វើតតិយសង្គាយនា ដូចសង្គាយនាទី១ និងទី២ដែរ ជាពិសេសលោកបានសំដែងកថាវត្ថុដោយពិស្ដារ ឯអសោកជាអ្នកឧបត្ថម្ភ; តតិយសង្គាយនានេះចាប់ធ្វើក្នុង (ខែទី៨ខាងមុខអំពី) ព-ស-២៣៤ឆ្នាំ, ៩ខែទើបចប់ ។

www.budinst.gov.kh www.elibraryofcambodia.org

រូបហើយដោយលោកយល់ថា៖ ពុទ្ធសាសនានឹងខ. ប្រតិស្ឋានក្នុងបច្ចន្តជនបទនោះ ទើបព្រះមោគ្គលីបុត្តតិស្សត្ថេរ បានចាត់ព្រះអរហន្តជាសមណទូតចំនួន៩ក្រុមក្នុងក្រុមនីមួយៗ មានភិក្ខុ ៥ រូបឲ្យទៅប្រកាសផ្សាយព្រះពុទ្ធសាសនាក្នុងបច្ចន្តជនបទដូចតទៅនេះគឺ៖

— ក្រុមទី១មានមជ្ឈន្តិកត្ថេរជាប្រធាន ទៅរដ្ឋកស្មីរនិងរដ្ឋគន្ធារ ។

— ក្រុមទី២មានមហាទេវត្ថេរជាប្រធាន ទៅរដ្ឋមហិសកមណ្ឌល ។

— ក្រុមទី៣មានរក្ខិតត្ថេរជាប្រធាន ទៅរដ្ឋវនវាសី ។

— ក្រុមទី៤មានយោនកធម្មរក្ខិតត្ថេរជាប្រធាន ទៅរដ្ឋអបរន្តកៈ ។

— ក្រុមទី៥មានមហាធម្មរក្ខិតត្ថេរជាប្រធានទៅមហារដ្ឋ ។

— ក្រុមទី៦មានមហារក្ខិតត្ថេរជាប្រធានទៅរដ្ឋយោនកៈ ។

— ក្រុមទី៧មានមជ្ឈិមត្ថេរជាប្រធាន ទៅដំបន់ក្បែរ

www.budinst.gov.kh www.elibraryofcambodia.org

ហាម័តាន្ត ។
េបា

— ក្រុមទី៨មានសោណកៈនិងឧត្តរត្ថេរជាប្រធាន ទៅសុវណ្ណភូមិ (១) ។

— ក្រុមទី៩មានព្រះមហិន្ទត្ថេរជាប្រធាន មានអរហន្ត ៤ រូបជាសមាជិកគឺ: ឥដ្ដិយត្ថេរ១ ឧត្តិយត្ថេរ១ សម្ពលត្ថេរ១ ភទ្ទសាលត្ថេរ១ ទៅតម្ពបណ្ណិទ្វីប ឬ លង្កាទ្វីប ។

ថា: ព្រះមហិន្ទត្ថេរនេះ មុននឹងទៅលង្កាទ្វីបជាមួយនិងអរហន្ត៤រូបនោះ លោកក៏យកព្រះអរហន្តមួយរូបទៀត នាមសុមនសាមណេរជាបុត្រនាងសង្ឃមិត្តាថេរី ដែលត្រូវជាក្មួយលោកនោះទៅជាមួយដែរ ។

តែដោយឧកាសមិនទាន់អនុញ្ញាតឲ្យលោកទៅភ្លាមៗ

---

(១) ភូមិភាគនៃដីសណ្ដរ មួយជ្រោយមានជាតិមាសច្រើន ហើយមានប្រវែងចំនួន៧០០យោជន៍ពីមជ្ឈិមប្រទេស នេះហៅថាសុវណ្ណភូមិ, បើទៅតាមសំពៅត្រូវខ្យល់៧ថ្ងៃ - យប់ទើបដល់, តែពេលខ្លះទៅតាមសំពៅដដែល ហើយគេឆ្លងកាត់តាមកំពង់ខ្ទង់ត្រីឈ្មោះនន្ទិយាវដ្ដ តែ៧ថ្ងៃក៏ដល់, (ឯកនិបាតគុត្តរនិកាយ៣ ផ្នែកថាត្រង់ជម្ពូទីបមេយ្យា៨) ។

www.budinst.gov.kh www.elibraryofcambodia.org

នោះ លោកក៏ថ្វាយបង្គំលាគ្រូនឹងព្រះសង្ឃ នាំអរហន្ត៥រូបនេះទៅសំចតនៅឯវេទិសនគរជាស្រុកញោមស្រីរបស់លោក ឯញោមស្រីនោះគ្រាន់តែក្រឡេកឃើញមុខកូនដល់មក ក៏ស្ទុះទៅឱបជើងយំ រួចសួរអំពីកូនស្រីនិងចៅផងដែរ ; ឯសុមន-សាមណេរក៏បង្ហាញខ្លួនភ្លាម សេដ្ឋីតានេះក៏ស្ទុះទៅស្ទើរតែត្រកងបីចៅនោះទៀត ។

រួចនាងរៀបចាត់ចែងចង្ហាន់ដោយដៃខ្លួនប្រគេន ក្នុងទីអាសាន ព្រះមហិន្ទត្ថេរសំដែងធម៌ប្រោសញោមស្រី បានសម្រេចសោតា និងភណ្ឌុកឧបាសកជាក្មួយជីដូនមួយរបស់លោក ក៏បានសម្រេចអនាគាមិផលក្នុងពេលនោះដែរ ។

មាតាលោកបានកសាងវត្តមួយ ឈ្មោះវេទិសមហាវិហារប្រគេនព្រះសង្ឃទាំងនេះគង់, លោកគង់នៅវត្តនេះអស់រយៈកាលចំនួន ៦-៧ខែ ទើបព្រះឥន្ទមកប្រគេនពត៌-មានថា: គួរនិមន្តទៅលង្កាទ្វីបចុះ ព្រោះឱកាសល្អហើយ នោះមហិន្ទត្ថេរ និងអរហន្ត៥រូបទៀត ក៏លាញោមស្រីហើយ

www.budinst.gov.kh www.elibraryofcambodia.org

យកទាំងគណ្ឋកនុបាសក ដាក់ក្នុយដីដូនមួយនោះហោះទៅលង្កាទ្វីប លោកទៅសំចតនៅលើភ្នំចេតិយគិរី នាបូព៌ាទិសក្រុងអនុរាធបុរីឯណោះ (មហិន្ទត្ថេរបួសបាន១២ វស្សាហើយ ព.ស.២៣៦) ។

ប្រវត្តិព្រះម.ស.នាខាងជម្ពូទ្វីបចប់

www.budinst.gov.kh www.elibraryofcambodia.org

# ១– ប្រវត្តិពុទ្ធសាសនាខាងលង្កាទ្វីប

មុនទីនឹងនិយាយពីប្រវត្តិនៃពុទ្ធសាសនា ដែលសាត់អណ្តែតពីជម្ពូទ្វីប ទៅដោតចំកណ្តាលកោះលង្កា ហើយជ្រាបចូលទៅក្នុងបេះដូងអ្នកស្រុក ដោយស្នាព្រះហស្តនៃសាស្ត្រាចារ្យឯកនាមមហិន្ទត្ថេរនោះ ៗ

ក៏គួរនិយាយពីប្រវត្តិនៃលង្កាទ្វីបនេះជាមុនសិនដែរ សូម្បីរឿងនេះជារឿងព្រេងក្តី ក៏គង់ជារឿងគួរស្តាប់ ហើយជាប្រេកពានៃពុទ្ធសាសនាផង ព្រោះជារឿងគួរបង់ដឹងផង ដោយរឿងនោះមានឧត្តមគតិទិន្នមនោគមវិជ្ជា ផ្នែកពុទ្ធសាសនាដ៏ពិសិដ្ឋណាស់ៗ

## ១. លង្កាទីបប្បវត្តិនិងពុទ្ធជំនឿ

ថាៈ កាលពីព្រេងនាយក្នុងសាសនាព្រះពុទ្ធកកុសន្ធោ លង្កាទ្វីបនេះ ហៅថាឧជទ្វីប, ព្រះរាជធានីមហាភិយ, នគរឈ្មោះអភ-

www.budinst.gov.kh www.elibraryofcambodia.org

យបុរៈ, ចេតិយបព៌តឈ្មោះទេវកូដ, ចូបារាមឈ្មោះបុជិយារាម។ ព្រះកកុសន្ធោព្រមទាំងព្រះអរហន្ត ចំនួន៤០.០០០រូប បាន និមន្តទៅទ្វីបនេះមុន ដើម្បីរម្ងាប់នូវបជ្ជរករោគ (រោគចុះរាក) របស់ប្រជាជន, លុះស្ងប់រម្ងាប់ហើយក៏ទ្រង់សំដែងធម៌ ទ្រង់ចូលនិរោធសមាបត្តិ ត្រង់ទីពោធិស្ថាន រួចទ្រង់អធិដ្ឋានឲ្យនាង រុចនន្ទាភិក្ខុនី ព្រមទាំងភិក្ខុនីឯទៀតចំនួន៥០០ និងពួកទេវតាផងនាំស្តេចខេមរាជពីខេមវតីរាជធានីទៅសាខាមែកព្រះជាមហាពោធិព្រឹក្សខាងភ្តាំ ដាក់ក្នុងផើងមាសយកមកថ្វាយស្តេចអភ័យ ដាំទុកក្នុងឧទ្យានឈ្មោះមហាមេឃវននាទ្វីបនោះ។

ព្រះកកុសន្ធោទ្រង់ប្រទានធម្មក្រក (សំពត់ត្រងទឹក) ឲ្យបញ្ចុះទុកក្នុងបង់យារាមចេតិយ និងទុកសាវកនាម មហាទេវត្ថេរ ព្រមទាំងភិក្ខុ១ ០០០រូប ឲ្យនៅប្រៀនប្រដៅអ្នកកោះនេះតទៅទៀត ព្រះអង្គត្រឡប់មកជម្ពូទ្វីបវិញ ។

លុះសាសនាព្រះកោនាគមន៍ ទ្វីបនេះប្រែឈ្មោះថាវរទ្វីប, ព្រះរាជានាម សមិទ្ធ នគរឈ្មោះវឌ្ឍមានៈ, ចេតិយ

www.budinst.gov.kh www.elibraryofcambodia.org

បពិតឈ្មោះសុវណ្ណកូដ ។

ព្រះពុទ្ធអង្គនេះព្រមទាំងអរហន្តចំនួន ៣០.០០០ រូបបាននិមន្តទៅទ្វីបនេះម្តង ដើម្បីរម្ងាប់ទុរ្ភិក្ស លុះរម្ងាប់ហើយក៏ទ្រង់សំដែងធម៌ ទ្រង់ចូលនិរោធសមាបត្តិត្រង់ទីពោធិស្ថាន ហើយទ្រង់ព្រះចិន្តា ឲ្យកណកទត្តាភិក្ខុនី ព្រមទាំងភិក្ខុនីឯទៀតចំនួន៥០០និងពួកទេវតាផង នាំព្រះបាទសោភពរាជ ពីសោភពរាជធានី ទៅសាកមែកខាងត្បូងព្រឹក្សជាមហាពោធិព្រឹក្សខាងស្តាំ ដាក់ក្នុងផើងមាស ដង្ហែយកមកថ្វាយស្តេចសមិទ្ធដាំទុកក្នុងឧទ្យានឈ្មោះមហាមេឃវននាទ្វីបនេះ ។ រួចទ្រង់ទុកមហាសុមត្ថេរព្រមទាំងភិក្ខុ ១.០០០ រូប និងទ្រង់ប្រទាននូវកាយពន្ធន៍ (វត្ថពន្ធបង្កេះ) ឲ្យបញ្ចុះទុកក្នុងសុវណ្ណកូដចេតិយនោះផង ព្រះអង្គត្រឡប់មកជម្ពូទ្វីបវិញ ។

លុះសាសនាព្រះពុទ្ធកស្សបៈ ទ្វីបនេះហៅមណ្ឌទ្វីបវិញ, ព្រះរាជានាម ជយន្តៈ. នគរឈ្មោះវិសាលៈ, ចេតិយបព៌តឈ្មោះសុភកូដ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះពុទ្ធកស្សបព្រមទាំងអរហន្តចំនួន ២០.០០០រូប បាននិមន្តទៅទ្វីបនេះម្តង ដើម្បីរម្ងាប់នូវមហាវិកទ (ជម្ងឺធំ) របស់ប្រជាជន, រួចទ្រង់សំដែងធម៌, ចូលនិរោធសមាបត្តិត្រង់ទីពោធិស្ថាន, រួចទ្រង់អធិដ្ឋានឲ្យនាងសុធម្មាភិក្ខុនីព្រមទាំងភិក្ខុនីឯទៀតចំនួន៥០០ និងពួកទេវតាផង នាំព្រះបាទព្រហ្មទត្តពីពារាណសីរាជធានី ទៅសាគមែកដៃជាមហាពោធិព្រឹក្សខាងស្តាំ ដាក់ក្នុងផើងមាសដង្ហែយកមកថ្វាយស្តេចជយន្តៈដាំទុកជាសក្ខីភាពក្នុងមហាមេឃវនឧទ្យាននាទ្វីបនេះ ។ រួចព្រះពុទ្ធកស្សប ទ្រង់ទុកសាវកនាម សព្វនន្ទត្ថេរ ព្រមទាំងភិក្ខុ១០.០០រូបឲ្យនៅក្នុងកោះនេះ ។ ហើយទ្រង់ប្រទាននូវឧទកសាដក (សំពត់ស្រង់ទឹក) ឲ្យបញ្ចុះទុកក្នុងចេតិយឈ្មោះសុភកូដនោះផង ព្រះកស្សបទ្រង់ត្រឡប់មកជម្ពូទ្វីបវិញ ។

លុះសម័យព្រះគោតម ទ្វីបនេះហៅថាលង្កាទ្វីប ឬតម្ពបណ្ណិទ្វីប (កោះរបស់មនុស្សដែលមានបាតដៃប្រឡាក់សុទ្ធដីក្រហម) ហើយនៅជាព្រៃមានសុទ្ធតែយក្សបិសាច មិន

មានមនុស្សនៅទេ, លុះក្នុងឆ្នាំដែលព្រះពុទ្ធអង្គនេះបរិនិព្វាន ទើបមានអាទិកជមួយនាម វិជ័យកុមារជាបុត្រសីហពាហុ មកតាំងនគរសោយរាជ្យក្នុងទ្វីបនេះ ។

តមកហៅថាសីហលទ្វីប (កោះដែលវិជ័យកុមារជាបុត្រសីហពាហុ មកនៅកាន់កាប់) នគរឈ្មោះអនុរាធបុរី, ចេតិយបព៌តឈ្មោះមិស្សកៈចេតិយ ឬ ចេតិយគិរី ។

ព្រះគោតមនេះមុនបរិនិព្វាន បាននិមន្តទៅទ្វីបនេះ៣លើកគឺ: ទី១-និមន្តទៅតែមួយអង្គឯង ទ្រង់ឈរលើអាកាសចំកណ្ដាលទីប្រជុំយក្សបិសាច និងចំកណ្ដាលកោះផង ទើបបណ្ដាលឲ្យកៀនខ្យល់យ៉ាងខ្លាំង ធ្វើឲ្យយក្សបិសាចរង៉ារញ៉ររន្ធត់ ត្រាតែមកសុំចុះចាញ់ប្រគេនទ្វីបទាំងមូលនេះមកព្រះអង្គដោយទ្រង់យល់ថា: សាសនាព្រះអង្គនឹងមកប្រតិស្ឋានក្នុងទ្វីបនេះ ទើបទ្រង់ធ្វើវក្កកម្មគឺនិមន្តថ្លុលទ្វីបអស់វារៈ ៣ ដុំ ដែលមានបណ្ដោយចំនួន៣យោជន៍ និងទទឹងប្រមាណ ១យោជន៍ វាតទីកន្លែងនេះទុកឲ្យមនុស្សនៅ; ហើយទ្រង់

www.budinst.gov.kh www.elibraryofcambodia.org

ប្រទាននូវវិមលកេសធាតុ (កេសធាតុមិនមានមន្ទិលមាន-ពណ៌ទៀត) ដល់ពួកយក្សបិសាចនោះ ក្នុងខែទី៩អំពីបានត្រាស់ ។

លើកទី២— ក្នុងឆ្នាំទី៥អំពីបានត្រាស់ទ្រង់និមន្តទៅម្ដងទៀត ទៅម្នាក់ឯង ដើម្បីទូន្មាននិងសម្រះសម្រួល ស្ដេចនាគទាំងពីរឈ្មោះចូឡោទរៈ និងមហោទរៈ ជាមានិងក្មួយទាស់គ្នាពីមណិបល្ល័ង្ក ។

លើកទី៣ - ក្នុងឆ្នាំទី៨អំពីបានត្រាស់ និមន្តទៅជាមួយនិងភិក្ខុចំនួន៥០០រូប ដោយមណិអក្ខនាគរាជអារាធនា ហើយទ្រង់ចូលនិរោធសមាបត្តិ ត្រង់មហាចេតិយដ្ឋាននិងថូបារាមចេតិយដ្ឋានជាដើម រួចទ្រង់ទុកស្នាមព្រះបាទលើភ្នំសុមនកូដផង ហើយទ្រង់ត្រឡប់មកជម្ពូទ្វីបវិញ ។

## ២- ខត្តិយវង្សលង្កាទ្វីបក្រុងអនុរាធបុរី

១- ក្នុងឆ្នាំដែលព្រះសម្ពុទ្ធបរិនិព្វាននោះ អាទិរាជនាម

www.budinst.gov.kh www.elibraryofcambodia.org

វិជ័យកុមារ ជាបុត្រសីហពាហុ ក៏មកកសាងនគរ តាំងនៅក្នុងកោះនេះដែរ ។

វិជ័យកុមារ(១)នេះ សោយរាជ្យបាន ៣៨ ឆ្នាំ ហើយសុគតក្នុងឆ្នាំទី ១៤ នៃរជ្ជកាលព្រះបាទឧទយភទ្ទនាជម្ពូទ្វីប (ព.ស.៣៨) ។

២– បណ្ឌុវាសុទេវ ជាក្មួយវិជ័យកុមារ សោយរាជ្យក្នុងឆ្នាំទី ១៥ នៃរជ្ជកាលព្រះបាទឧទយភទ្ទនាជម្ពូទ្វីប ។ អគ្គមហេសីស្តេចនេះ នាមព្រះនាងភទ្ទកាញ្ចនា ជាចៅអមិតោ-ទនសាក្យៈ, ស្តេចនិងព្រះនាងនេះមានបុត្រ ១០ រូបនិងបុត្រីមួយផង ; សោយរាជ្យបាន ៣០ ឆ្នាំ ហើយសុគតក្នុងឆ្នាំទី ២០នៃរជ្ជកាល ព្រះបាទនាគទាសកៈនាជម្ពូទ្វីប(ព.ស.៦៨) ។

៣- ក្នុងឆ្នាំទី ២០ នោះ អភ័យកុមារជាបុត្របណ្ឌុ-

---

(១) វិជ័យកុមារនេះជាពូជក្សត្រក្លិង្គៈ; ជាមុនពុទ្ធកាល ស្តេចក្លិង្គនាមវង្គៈនិងព្រះនាងកាលិង្គរាជធីតាក្នុងវង្គនគរ មានបុត្រីមួយនាមផ្ទួចមាតាដែរ ហោរាទាយថា បុត្រីនេះនឹងបានសត្វរាជសីហ៍ជាប្តី មាតាបិតាអៀនខ្មាសក៏និរទេសបុត្រីនេះចេញ

ក្នុង ---

www.budinst.gov.kh www.elibraryofcambodia.org

បុត្រីនេះបានដោយសារនិងពួករទេះ ទៅជួបនិងរាជសីហ៍បានគ្នាជាប្ដីប្រពន្ធ បានបុត្រមួយនាមសីហពាហុ និងបុត្រីមួយនាមសីហសិវលី លុះកុមារនេះអាយុ ១៦ ឆ្នាំ ក៏នាំមាតានិងប្អូនស្រីរត់មកស្រុកដីខ្លួនដើម សេនាបតីម្នាក់បានយកមាតារបស់កុមារ-កុមារិកានេះជាភរិយា ក្រោយនេះរាជសីហ៍មកតាម ស្ដេចជីតាឲ្យសីហពាហុជាទៅចេញតយុទ្ធ រាជសីហ៍ភ្ញាក់មាត់ប្រមាថកូនឯងត្រូវសរស្លាប់, រួចគេលើកសីហពាហុធ្វើស្ដេច តែកុមារនេះបានប្រគល់រាជសម្បត្តិថ្វាយមាតាវិញ, មាតាបានផ្សំបុត្រ-ធីតានេះជាស្វាមីភរិយាៗថ្មីនេះព្រមទាំងពលខ្លះ ក៏លាមាតាមកសាងបុរីថ្មី ត្រង់ទីដែលរាជសីហ៍ជាបិតាខ្លួននោះនៅ បុរីថ្មីនេះឈ្មោះសីហបុរី ។ក្រោយមក ។ ក្សត្រពីរនាក់បងប្អូននេះមានបុត្រ ៣២ រូប មានវិជ័យកុមារនេះជាដើម ដោយវិជ័យកុមារមានអាចារៈមិនសូវល្អគេស្អប់ច្រើន មាតាបិតាក៏និរទេសចេញជាមួយនិងបរិវារ ៧០០ នាក់ ព្រមទាំងភរិយានិងកូនក្មេងស្រីប្រុសប៉ុណ្ណោះដែរ ឲ្យកោរទ្វេក្បាលដាក់ក្នុងសំពៅនីមួយៗ ជាពួកៗ បណ្ដែតចោលក្នុងសមុទ្រទៅ។

សំពៅកូនក្មេងអណ្ដែតទៅជាប់និងនគ្គទ្វីប (កោះស្រីលវោ), សំពៅស្រីៗ ជាភរិយាអណ្ដែតទៅជាប់និងមហិទ្លាទ្វីប (កោះស្រីវិជ័យ-ថ្នាសូមាត្រា), ឯសំពៅវិជ័យកុមារអណ្ដែតទៅជាប់និងលង្កាទ្វីប (កោះដែលគេហៅតទៀតពីសំពៅទៅនៅ) ៗ

វិជ័យកុមារបានយកស្រីយក្សជាមេកោះនោះឈ្មោះនាង កុវេណា ជាភរិយា បានបុត្រមួយនាម ជីវហត្ថ និងបុត្រីមួយនាម សល្លទាមិកា, ដោយវិជ័យកុមារប្រុងរៀបអភិសេកអគ្គមហេសីថ្មីទៀត ក៏លែងនាងកុវេណាះចោល នាងនេះនាំកូនពីរនាក់ដើរក្នុងកោះគេវាយនាងស្លាប់ ឯកូនពីរនាក់គេចខ្លួនរួច កូនទាំងពីរនាក់នេះបានយកគ្នាជាប្ដីប្រពន្ធ មកនៅក្នុងមលយជនបទ (ថ្នាមាលយូ)។

www.budinst.gov.kh www.elibraryofcambodia.org

សុទេវៈ ដោយរាជ្យតមកទៀតអស់រយៈ ២០ ឆ្នាំ រហូតដល់ឆ្នាំទី ១៧ នៃរជ្ជកាលព្រះបាទសុសុនាគ នាជម្ពូទ្វីប (ព.ស.៨៨)។

៤- ក្នុងឆ្នាំទី ២០ នៃរជ្ជកាលអភ័យកុមារនោះ មានទាមរិកនាមបណ្ឌុកាភ័យ ជាក្មួយច្បាំងដណ្តើមយករាជ្យ ។ បណ្ឌុកាភ័យ(២)នេះ ធ្វើស្តេចបាន ១៧ ឆ្នាំ រហូតដល់ឆ្នាំទី១៦ នៃរជ្ជកាលព្រះបាទកាឡាសោកនាជម្ពូទ្វីប បើរួម ១ ឆ្នាំខាងក្រោយផងជា ១៨ ( ធ្វើស្តេចមិនមានគេអភិសេក), ដោយរាជ្យបាន ៧០ ឆ្នាំទៀត ហើយសុគតក្នុងឆ្នាំទី ១៤ នៃរជ្ជកាលព្រះបាទចន្ទគុត្តនាជម្ពូទ្វីប ( ព.ស ១៧៦ ) ។

៥– ព្រះបាទមុដ្ឋសីវៈ ជាបុត្របណ្ឌុកាភ័យនិងព្រះនាងសុវណ្ណបាលិ មុដ្ឋសីវៈនេះ មានបុត្រ ១០ រូបនិងបុត្រីពីររូប ដោយរាជ្យបាន ៦០ ឆ្នាំ ហើយសុគតក្នុងឆ្នាំទី ១៧ នៃរជ្ជកាលអសោកនាជម្ពូទ្វីប ( ព.ស-២៣៦ ) ។

---

(២) ស្តេចនេះជាបុត្រនាងចិត្តានិងអយ្យបុត្រនាមទីឃគាមណី ជានាង

ឆ្ងិ- - -

ចិត្តកានេះជាបុត្រីពៅរបស់ស្តេចបណ្ឌុរាសុទេវរាជនិងព្រះនាងភទ្ទកញ្ញា ៗ ហោរា ទាយថា៖ នាងពៅនេះបើមានបុត្រ ៗ នោះនឹងសម្លាប់ឪពុកធំដករាជ្យ , នោះ បងៗ ទាំង ៩ នាក់រកលេសសម្លាប់នាងពៅ តែអភ័យកុមារជារាមច្បងមិនព្រម ។ គេឱ្យនាងពៅនៅតែក្នុងប្រាសាទសសរមួយនិងស្រីគមម្នាក់នៅរក្សា · មនុស្ស ១០០ នាក់យាមជុំវិញ មានតែទ្វារមួយចេញមកបន្ទប់ស្តេច ។ ថាទីឃ-គាមណីជាក្មួយមាតានាងពៅនេះបានទៅនៅគាល់ស្តេច, ដោយស្រីគមឱ្យការផង យប់ ៗ គេជិះយន្តក្តាមចូលតាមពន្លឺះទ្វារ ទៅរួមសំវាសនិងនាងពៅទាល់តែមាន គភ៌, មាតា-បិតានាងពៅឥតយកទោសទេ តែបង ៗ ទាំង ៩ ថា៖ បើកូននាងពៅ ប្រុសសម្លាប់ចោល ។ ថាស្វាមីនាងពៅឱ្យមនុស្សពីរនាក់មករក្សា បង ៩នាក់ ឱ្យគេសម្លាប់មនុស្សពីរនាក់នេះ ៗ ស្លាប់ទៅកើតជាយក្សតាមរក្សាបុត្រនាងពៅ ទៀត ។ ថាគេប្តូរបុត្រនាងពៅនិងបុត្រីស្រីម្នាក់ក្នុងមន្ទីរពេទ្យបពេក្ខះអាសន្ន ។ ថាពេលនោះបិតានាងពៅសុគត ហើយឱ្យអភ័យកុមារជារាមច្បងសោយរាជ្យ ។ ថានាងពៅឱ្យទាសីយកបុត្រនាងដាក់ក្នុងស្មុគយកទៅលាក់ស្រុកក្រៅ ទាសីនេះ ទៅប្រទះនឹងបង ៗ ទាំង ៩ កំពុងប្រពាធព្រៃគេហៅដែក ។ ឯយក្សពីរដែល តាមរក្សាទារក-និម្មិតជាជ្រូក,បង ៗ ទាំង៩នោះដេញបាញ់ជ្រូក ទាសីក៏យកទារក រត់ទៅផ្ញើនឹងនាយស្មៀន ៗ ឃោសនាថាប្រពន្ធគេសម្រាលកូនភ្លោះ ។ លុះ បុត្រនាងពៅនេះអាយុ ៧ ឆ្នាំទៅងូតទឹកនឹងក្មេង ៗ បងនាងពៅស៊ើបដឹងបញ្ជា ឱ្យសម្លាប់ក្មេង ៗ អស់ ឯកូននាងពៅពួនក្នុងស្រះនាវន្ធឈើមួយរួចខ្លួន,ក្រោយ នេះបងនាងពៅបញ្ជាឱ្យនាយគោបាល បញ្ឆោតបុត្រនាងពៅទៅរកភ្លើងឯផ្ទះ

ជ្និង - - -

www.budinst.gov.kh www.elibraryofcambodia.org

កុមារនេះមកប្រើប្អូនស្មៀន បន្តមកទៀត គេស្មានខុសសម្លាប់ប្អូនស្មៀននោះទៅ ។ លុះអាយុ ១៦ ឆ្នាំនាងពៅលបបញ្ជូនប្រាក់ទាំងពាន់ ៗ ឱ្យនាយស្មៀនរក្សានិងឱ្យបុត្រនេះទៅរៀន ក្នុងសំណាក់មណ្ឌលព្រាហ្មណ៍ជាមួយនឹងចន្ទកុមារជាប្អូនព្រាហ្មណ៍នោះ ។ ចាព្រាហ្មណ៍នេះបានចំណាយប្រាក់និងកេណ្ឌទ័ពឱ្យបាន ៥០០ នាក់រួចផ្តាំថា: បើរាជកុមារ ប្រទះស្រីក្រមុំណាកាន់ស្លឹកឈើ ៗនោះក្លាយជាមាសអ្នកយកនាងនោះជាភរិយាចុះ រួចតាំងចន្ទប្អូនខ្ញុំនេះជាបុរោហិត ។ បុត្រនាងពៅនេះកេណ្ឌទ័ពបានច្រើនទៀត រួចទ្រៀមក្បែរគីរិកណ្ណកបពិត, គុះឃ្មានាងសុវណ្ណបាលិជាបុត្រីគីរិកណ្ណសីវៈ ដែលជាឪពុកធំគេនោះ គង់យានមកហើយ គេស្ទុះទៅស្ទាក់មុខយានសួរនាមនិងការណ៍សព្វគ្រប់ រួចគេសុំភត្តដែលនាងបំរុងយកទៅថ្វាយបិតាងស្រែនោះ នាងដាក់ភត្តនិងភាជន៍មាសឱ្យ, យកស្លឹកជ្រៃចកដាក់ភត្តឱ្យពេលនោះទៀត នោះស្លឹកឈើក្លាយទៅជាមាសទាំងអស់ រួចគេនាំនាងនេះគេចពីទីនេះទៅ ។ បិតានាងនេះបញ្ជាឱ្យមនុស្សនិងប្អូនប្រុស ៥ នាក់ទៅតាម តែនាយចន្ទពិឃាដអស់, លើកតែអភ័យរាជចេញ បងនាងពៅទាំងអស់សុទ្ធតែចេញតយុទ្ធ-តែមិនមានជ័យជំនះ ។ ពួកគេទោទស្តេចបងថា: ប្រើរហស្សបាយជាមួយនាងពៅ តែរកលេសពិឃាដ ស្តេចបង ៗ ក៏ដាក់រាជ្យឱ្យអនុជទាំងនោះ ។ ក្រោយនេះបិតានាងសុវណ្ណបាលិឈប់ចូលនិងបងប្អូន ៨ នាក់ហើយ, ឯបណ្តាភ័យជិះលាយក្បួចូលតយុទ្ធឪពុកធំទាំង៨ស្លាប់អស់ ។ ទ្រង់ឱ្យលាងស្មេគ្រជ័គ្រយកទឹកមកអភិសេកខ្លួននឹងនាងសុវណ្ណបាលិ រួចតាំងអភ័យរាជជាមេនគរបាល, ប្រទានគីរិកណ្ណកជនបទដល់ឪពុកក្មេក,តាំទីបុរោហិតដល់នាយចន្ទ, ឋានន្តរស័ក្តិដល់ពួកពល ។

www.budinst.gov.kh www.elibraryofcambodia.org

៦- ព្រះបាទទេវានម្បិយតិស្សៈ ជាបុត្រទីពីរនៃព្រះបាទមុដសីវៈ សោយរាជ្យក្នុងឆ្នាំទី ១៨ នៃរជ្ជកាលអសោក(ព.ស. ២៣៦ និង ២៣៧) ។ តាមអនុសាស្ត្រនៃខត្តិយវង្សនេះ បណ្ឌិតត្រូវយល់ថា: ព្រះសម្ពុទ្ធបរិនិព្វានបាន ២៣៦ ឆ្នាំ ទើបព្រះមហិន្ទត្ថេរទៅប្រតិស្ឋានពុទ្ធសាសនាក្នុងលង្កាទ្វីប ។

## ៣- ធាតុនិធាននិងសាសនារបស់ព្រះគោតម

មុនពិតពេលដែលមហិន្ទត្ថេរ និងសមាជិក ៦ រូបទៀត ហោះទៅដល់លង្កានោះ ព្រះបាទទេវានម្បិយតិស្សៈ(៣) ទើបរាជាភិសេកបាន ១ ខែប៉ុណ្ណោះ ។ ស្តេចទេវានិងអសោកជាមិត្រជិតស្និទ្ធ ប៉ុន្តែមិនដែលបានជួបគ្នាផ្ទាល់ទេ គ្រាន់តែ

---

(៣) ជាតិអតីតកាលមានបងប្អូន ៣ នាក់ជាឈ្មួញទឹកឃ្មុំ គឺបងពីរនាក់ជាអ្នកដឹកនាំមកឲ្យ,ប្អូនពៅជាអ្នកលក់ ។ គ្រានោះមានព្រះបច្ចេកពុទ្ធមួយអង្គទៅរកទឹកឃ្មុំមកធ្វើថ្នាំ បានជួបនិងនាងកុម្ភទាសី (ឈ្មួលស្រីដងទឹក) ម្នាក់, នាងបង្អុលប្រាប់ថា: សូមព្រះគុណម្ចាស់និមន្តទៅរកអ្នកលក់ទឹកឃ្មុំឯណោះចុះ បើគេប្រគេន

ឆ្លង ---

ឬមិនប្រគេនឬគេហៅថាដូចម្ដេច លុះវិលមកវិញប្រាប់ខ្ញុំករុណាផង ។ ឯអ្នកលក់ទឹកឃ្មុំប្រគេនទាល់តែពេញប្លោរហៀរហូរ ក៏ប្រាថ្នាថា: សូមឲ្យបានជាស្ដេចឯករាជ្យមានអំណាចទៅលើអាកាសនិងក្នុងដីចំនួន១យោជន៍, លោកថា: សូមឲ្យក្ដីប្រាថ្នានេះបានសម្រេចចុះ ។ អ្នកលក់ទឹកឃ្មុំនេះលុះមកផ្ទះប្រាប់បងទាំងពីរឲ្យអនុមោទនា. បងច្បងទី១ថា: សូម្បីជនចណ្ឌាលក៏ចេះស្លៀកពាក់សំពត់កាសាវពស្ត្រដែរ ក្រែងជនទទួលទឹកឃ្មុំពីប្អូនឯងទៅនោះជាជនចណ្ឌាល គេទៅស្រុកចណ្ឌាលបាត់ហើយទេដឹង? ឯបងកណ្ដាលទី២ថា: ប្អូនឯងទៅចាប់ព្រះបច្ចេកពុទ្ធនោះបោះចោលក្នុងត្រើយនាយសមុទ្រទៅ ។ ប៉ុន្តែក្រោយភ្លាមនោះបងទាំងពីរបានស្ដាប់ទាននានិសង្ស ដែលប្អូនពៅនិយាយប្រាប់ ក៏អនុមោទនាយកដោយរីករាយ ។ ឯព្រះបច្ចេកពុទ្ធលុះបានទឹកឃ្មុំហើយ ក៏វិលមកជួបនិងនាងកុម្ភទាសីប្រាប់តាមដំណើរដែលអ្នកលក់ទឹកឃ្មុំប្រាថ្នា នោះនាងកុម្ភទាសីយកក្រមាថ្មីខ្លួនដែលខ្លួនផ្ដាប់ប្រគេនរួចប្រាថ្នាថា: ដោយអានុភាពនៃវេយ្យាវច្ចកម្មនិងចីវរទាននេះ ខ្ញុំករុណាសូមឲ្យមានរូបសម្បត្តិល្អបំផុត ព្រមទាំងយសសក្តិនិងសិរីសម្បត្តិដ៏ពិសិដ្ឋ បើអ្នកលក់ទឹកឃ្មុំនោះបានជាស្ដេចចុះខ្ញុំករុណា សូមឲ្យបានជាអគ្គមហេសីស្ដេចនោះកុំខាន លោកថា; សូមឲ្យក្ដីប្រាថ្នានេះបានសម្រេចចុះ។បងច្បងគឺនិគ្រោធសាមណេរ (ដោយទោសប្រមាថព្រះបច្ចេកពុទ្ធថា "ជនចណ្ឌាល, បានជាសាម-ណេរនេះទៅប្រសូតក្នុងស្រុកចណ្ឌាល), បងកណ្ដាលគឺស្ដេចទេវានម្បិយតិស្សៈ (ដោយទោសពោលទ្រគោះបោកបោះទៅលើព្រះបច្ចេកពុទ្ធថា : ចាប់បោះចោលក្នុងត្រើយខាងសមុទ្រ; បានជាស្ដេចនេះកើតក្នុងកោះលង្កា), ប្អូនពៅជាអ្នកលក់ទឹកឃ្មុំ គឺអសោក, ឯនាងកុម្ភទាសី គឺព្រះនាងអសន្ធិមិត្តា ។

www.budinst.gov.kh www.elibraryofcambodia.org

ផ្សុបណ្ណការថ្វាយគ្នាទៅវិញទៅមក ស្តេចនេះមានបុញ្ញានុភាពផិតប្រហែលអសោកដែរ ។ ថា: មានដើមឬស្សី ៣ដើមប្រមាណប៉ុនដងទង់រថ កើតសម្រាប់ស្តេចនេះគឺ, ១- ឈ្មោះលតាយដ្ឋិ ដើមមានពណ៌ចេញមកជាប្រាក់ ឯមែកចេញមកជាមាស, ២- បុប្ផយដ្ឋិ មានផ្កា ៥ ពណ៌ ហើយមានកេសរផ្ទះពោយពាយគ្រប់បណ្តុយល្អប់, ៣- សកុណយដ្ឋិ មើលទៅដូចជាសត្វចតុប្បាទនិងរូបភាពនៃសត្វស្លាបឯទៀត មានហង្ស-មាន់-ព្រាហ៊ុតជាដើម, ហើយមានរតនជាតិជាអនេក-អនេក្យកើតសម្រាប់ស្តេចនេះផង ។

សម័យដែលពជាភិសេករួចបាន ១ខែ ស្តេចនេះបានយានទៅក្រសាលព្រៃក្នុំចេតិយគិរី ដួចនឹងព្រះមហិន្ទត្ថេរក្នុងព្រៃក្នុំនោះ ។

មហិន្ទត្ថេរ - . - មហាពជ ! មានជនជាសាច់ញាតិមកច្រើនដែរ ឬ ?

ព្រះរាជា - . . ទាន ប្រោសមានច្រើនដែរ ! ។

www.budinst.gov.kh www.elibraryofcambodia.org

មហិន្ទត្ថេរ . . . ចុះបើលះបង់សាច់ញាតិនោះទៅ មាន ជនណាដទៃមិនមែនជាសាច់ញាតិដែរ ឬ ?

ព្រះរាជា - - - មានប្រុសជនមិនមែនជាសាច់ញាតិ មានច្រើនណាស់ ! ។

មហិន្ទត្ថេរ - - - ចុះបើលះបង់សាច់ញាតិនិងលះបង់ជន មិនមែនជាសាច់ញាតិទៅ តើមានជនដទៃណាមួយទៀត ដែរ ឬទេ ?

ព្រះរាជា - - មានប្រុសមានតែខ្ញុំករុណាហ្នឹងឯង ! ។

មហិន្ទត្ថេរ - - ប្រពៃណាស់មហារាជ ! ធម្មតាខ្លួនយើង ជាជាសាច់ញាតិរបស់ខ្លួនក៏មិនមែន ជាមិនមែនជាសាច់ញាតិ របស់ខ្លួនក៏មិនមែន (គឺខ្លួនត្រូវតែពឹងខ្លួន) ។ រួចលោកសំដែង ចូឡហត្ថិបទោបមសូត្របន្តទៅទៀត ឲ្យស្ដេចនិងសេនាមាត្យ ចំនួន៤០.០០០នាក់ឋិតក្នុងសរណគមន៍និងសីល៥ទាំងអស់ ។

ព្រះរាជាជ្រះថ្លាណាស់ ក៏ទ្រង់និមន្តទៅទីក្រុង តែ មហិន្ទត្ថេរៈមិនទាន់ព្រមនិមន្ត ។

www.budinst.gov.kh www.elibraryofcambodia.org

អញ្ចឹងស្អែកខ្ញុំករុណាឲ្យយករថមកទទួល ហើយថ្វាយបង្គំលាទៅ ។

រាត្រីនោះព្រះមហិន្ទត្ថេរ បញ្ជាឲ្យសុមនសាមណេរឃោសនាធម៌ លោកនេទៈនេះក៏ចូលចតុត្ថជ្ឈាន អធិដ្ឋានឲ្យអ្នកលង្កា និងទេវតា-គ្រុឌ-នាគ ព្រមទាំងព្រហ្មលោក បានឮសំឡេងប្រកាសធម៌នោះទាំងអស់ ។

ព្រលឹមស្រាងឡើងគេឃើញ សារថីបររថទៅនិមន្តព្រះថេរៈទាំងឡាយនោះ ។ ព្រះថេរៈទាំងនោះថា ៖ ចូរសារថីទៅមុនចុះអាត្មាភាពនឹងទៅតាមក្រោយ ។

ស្រាប់តែអរហន្តទាំងនោះ ហោះមកដល់បឋមចេតិយក្បែរទីក្រុងមុនសារថីនោះ ។ មហាស្ចារ្យនេះនាំឲ្យស្ដេចនិងអ្នកក្រុង រឹតតែជ្រះថ្លានិងស្ងើចយ៉ាងខ្លាំង ។

ព្រះរាជាលុះថ្វាយបង្គំហើយ ក៏និមន្តទៅក្នុងព្រះរាជ-និវេសន៍ លុះអង្គាសចង្ហាន់រួច មហិន្ទត្ថេរសំដែងទេវទូតសុត្ត. លុះចប់ធម្មទេសនានោះ មានស្ត្រី ៥០០ នាក់បានសម្រេច

www.budinst.gov.kh www.elibraryofcambodia.org

ស្រោតាបត្តិផល, ហើយសំដែងទៅទៀតឥតក្រៃទៀត លុះបញ្ចប់ មានមហាជនចំនួន ១.០០០ នាក់ បានសំរេចស្រោតាបត្តិផលដែរ ។

ព្រះរាជាទ្រង់ទុកមហាមេឃវនុយ្យាន ជាអារាមសម្រាប់សំចតនៃព្រះអរហន្តទាំងនោះ ។

លុះថ្ងៃទី ៧ ក៏និមន្តទៅចេតិយគិរីវិញ ចាំវស្សានៅទីនោះ នៅថ្ងៃចូលវស្សានោះមានសេនាមាត្យឈ្មោះមហាអរិដ្ឋព្រមទាំងបងប្អូន ៥៥ នាក់ បួសក្នុងសំណាក់ព្រះថេរៈ, ហើយបានសម្រេចព្រះអរហត្តក្នុងខណៈខុរគ្គកិច្ចទាំងអស់ ។

ក្នុងវស្សានោះមានព្រះអរហន្តចំនួន ៦២ អង្គ ។

លុះថ្ងៃពេញបូណ៌មីខែកត្តិក ចេញវស្សាហើយ មហិន្ទត្ថេរៈធ្វើកិច្ចថា: អាត្មាភាពទាំងឡាយ ចង់ត្រឡប់ទៅជម្ពូទ្វីបហើយ ព្រោះរលឹកព្រះសម្ពុទ្ធណាស់ ! ។

ព្រះរាជា... ចុះព្រះសម្ពុទ្ធទ្រង់បរិនិព្វានហើយឬ? ។

មហិន្ទត្ថេរៈ... ព្រះសម្ពុទ្ធបរិនិព្វានមែន ! ប៉ុន្តែព្រះ

www.budinst.gov.kh www.elibraryofcambodia.org

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ារីរិកធាតុរបស់ព្រះអង្គចុះនៅឡើយ ។

ទេ ! ខ្ញុំករុណាចង់និមន្តព្រះសារីរិកធាតុមកប្រតិស្ឋានក្នុងនគរនេះ តែមិនដឹងជាបានព្រះសារីរិកធាតុនោះពីណា ? ។

មហាបពិត្រ ... បើព្រះបំណងដូច្នោះ សូមទ្រង់ពិភាក្សានឹងសុមនសាមណេរមើល ? ។

សុមនសាមណេរ ... សូមទ្រង់ផ្ដាស់ផ្ដាតគង់-នគរឲ្យព្រោងព្រាតចុះ, សូមស្អាតមានរបៀបស់ម, សូមរៀបចំដីមន្ទីរលទ្ធិ ស្ទូត្រឆត្រ, និងទង់ប្រដាប់ផង, ជម្រះវិថីឲ្យស្អាតល្អ, រួចថ្ងៃរសៀលសូមទៅរង់ចាំក្នុងមហាមេឃវ័នឧទ្យានចុះ, នោះទ្រង់នឹងបាននូវព្រះសារីរិកធាតុមិនខាន ។

ដោយបានទទួលព្រះថេរដីកាពីលោកដូច្នេះហើយ សុមនសាមណេរនេះក៏ហោះទៅជួបព្រះអសោកធម្មរាជ សុំព្រះសារីរិកធាតុទាំងឡាយ បានហើយក៏ហោះទៅជួបព្រះឥន្ទ សុំព្រះទក្ខិណក្ខកធាតុ (ឆ្អឹងដងកាំបិតស្ដាំ) បានទៀត ហើយត្រឡប់ទៅដល់ចេតិយគិរីបព្វតវិញភ្លាម ។

www.budinst.gov.kh www.elibraryofcambodia.org

គ្រានោះអរហន្តព្រមទាំងស្តេច-ប្រជាជន-ទេវតា រៀបក្បួនដង្ហែព្រះធាតុនោះ អឹកធឹកអស្ចារ្យណាស់, ដោយព្រះរាជាទ្រង់ទូលនូវក្បួនផ្កាសំពប់ទ្រព្រះធាតុ ហើយទើបយកទៅដាក់លើពោធិ៍ដីមណ្ឌល, ឯដីរាំរែកកាយក៏ស្រែកកងរំពងទាំងភ្នំជុំវិញព្រឹក្សត្រស័ក្តិកឹបទ្ទឹយ៉ាងទ្រហឹង មហាមេឃក៏បន្លឺរគ្រៀងឥតទទឹក, ពសុធាក៏ញ័រដល់បាតសមុទ្រ ។

រួចគេហែ ជុំវិញទីក្រុង ហើយឆ្ពោះមុខទៅបូជាកមចេតិយ, ស្រាប់តែធាតុនោះអណ្តែតពីក្បាលដំរី ទៅលើអាកាសចំនួន៧ជួរដើមត្នោត សំដែងនូវបាដិហារ្យគួរឲ្យអស្ចារ្យពន់ពេក ទើបធ្លាក់ចុះមកប្រតិស្ឋាន ក្នុងបរិភោគចេតិយដ្ឋានរបស់ព្រះពុទ្ធទាំង៧អង្គអំពីបូរាណ នាភាគខាងត្បូងក្រុងអនុរាធបុរី ។

ដោយភក្តិជ្រះថ្លានិងបាដិហារ្យនេះ គេឃើញអនុជរបស់ស្តេច នាម អភ័យរាជកុមារ ព្រមទាំងបុរសចំនួន១.០០០រូបបួសក្នុងពេលនោះភ្លាម, បន្ទាប់មកគេៈឃើញយុវជនចេញពី

www.budinst.gov.kh www.elibraryofcambodia.org

ក្រុងនិងក្រៅក្រុងមកបួស ជាភិក្ខុមានចំនួន ៣០.០០០រូបដែរ ។

លុះបូជានិងប្រតិស្ឋានព្រះសារីរិកធាតុរួចហើយ ព្រះមហិន្ទត្ថេរក៏និមន្តទៅចាំវស្សា នៅនាឧទ្យានឈ្មោះមហាមេឃវ័ន ។

សម័យនោះព្រះនាងអនុឡាទេវី ជាអគ្គជាយាពមហ្សង៍របស់ស្តេច ព្រមទាំងនាងកញ្ញាចំនួន១,០០០រូបចង់បួស; ព្រះរាជាក៏ស្នើការនេះនិងព្រះមហិន្ទត្ថេរ ។

ព្រះមហិន្ទត្ថេរ ក៏បញ្ជាឲ្យស្តេចប្រើអរិដ្ឋអាមាត្យ ជាក្មួយស្តេចដែលចង់បួសដែរនោះ ទៅក្រុងបាដលិបុត្រនិមន្តព្រះសង្ឃមិត្តាថេរី មកបំបួសនាងកញ្ញាទាំងនេះ ។

ដោយយកនូវសាសនបណ្ណ (សំបុត្រខាងសាសនា)របស់ស្តេចនិងព្រះមហិន្ទត្ថេរទៅផង ដីដោយបុណ្យានុភាពរបស់ព្រះថេរៈផង អរិដ្ឋអាមាត្យទៅកំពង់ផ្លូវគោលៈ ដិះសំពៅទៅតែ១ថ្ងៃប៉ុណ្ណោះ ក៏ដល់ទៅក្រុងបាដលិបុត្រ ។

ទិកកាលនោះ អរិដ្ឋអាមាត្យបានឡើងគាល់អសោក

www.budinst.gov.kh www.elibraryofcambodia.org

ហើយសា ស័ទ្ធខ្ញុំពិតជាមានសព្វគ្រប់ អំពីគ្រឿងបំណាក់នៃស្តេច របស់ខ្លួនទាំងព្រះមហាវិហារ. រួចទើបទៅថ្វាយបង្គំព្រះសង្ឃ-មិត្តាថេរី ទាំងថ្វាយនូវសាសនបណ្ណនោះផង ។

ព្រះថេរីក៏យកសាសនបណ្ណនោះ និមន្តទៅគាល់ថ្វាយ អសោកជា: ញាមថា: មហាក្សត្រជាបង្គំ (ទាំងស្តេចក្រុងលង្កា) សូមនិមន្តព្រះសង្ឃមិត្តាថេរីជាប្អូនទៅលង្កាទ្វីប ដើម្បីបំបួសកញ្ញាចំនួន ១.០០០រូប មានព្រះនាងអនុឡាទេវីជាដើម, ហើយសូមព្រះនាងសុំឲ្យញាមយើង សាគយកនូវមែកពោធិព្រឹក្សទៅជាមួយផង ព្រោះអ្នកលង្កាចង់បានយកទៅប្រតិស្ឋានក្នុងទ្វីបនេះ ។

ព្រះអសោក . . . លោកកូនអើយ ! មហាក្សត្រទាំងសុមនសាមណេរ ជាបុត្រទាំងចៅខ្ញុំករុណាទៅលង្កាផុត ដូចគេកាត់ដៃខ្ញុំករុណា ១ ទឹកបុត្រទាំងចៅពន់ពេកណាស់ ! ក៏ក្រៀមក្រំចិត្តរបស់ខ្ញុំករុណាស្ងប់បន្តិចនោះ ដោយមានលោកកូននៅគង់ជិត ក្រោយលោកកូនស្រីក៏និមន្តទៅទៀត ! ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះសង្ឃមិត្តាថេរី ព្រះពុទ្ធដីការបស់បងអាត្មា មានទម្ងន់ណាស់ ទាំងនាងខត្តិយរាជកញ្ញាទាំងឡាយ មានអនុឡាទេវីជាដើម ចំនួន ១០០០រូប ដែលចង់បព្វជ្ជានោះ ក៏រង់ចាំដើរផ្លូវអាត្មាភាពដែរ អាត្មាភាពគួរតែទៅ ។

ឥលោតថា៖ អ ភ្លីា លោកកូនស្រីនិមន្តក៏និមន្តចុះ យកព្រះមហាពោធិព្រឹក្សទៅជាមួយផង ។

ចុះព្រះបាទអសោកៈ បាននាំយកព្រះមហាពោធិព្រឹក្សនេះដោយណាមក។ ថា ដីមុននោះ តាំងពីមុនសាមណេរ មិនទាន់មកយកព្រះសារីរិកធាតុផង អសោកប្រុងនឹងបញ្ជូនព្រះមហាពោធិព្រឹក្សដែលគេមិនគួរកាត់ដោយកាំបិតទៅលង្កាទ្វីបម្តងហើយ ដោយលោកតក់ក្រហាយមិនទាន់ឃើញ ហើយលោកសួរទៅមហាទេវអាមាត្យ ។ អាមាត្យនោះថា អោយសួរព្រះបញ្ញតភិក្ខុទាំងឡាយ ។

ភិក្ខុទាំងឡាយប្រគល់ភារៈនេះអោយទៅព្រះមោគ្គលីបុត្តតិស្សត្ថេរ ព្រះមោគ្គលីបុត្តតិស្សត្ថេរទូលថា បពិត្រមហារាជភារលោកបញ្ជូននូវដែមកព្រះមហាពោធិព្រឹក្សទៅលង្កាទ្វីប គួរពិចារណានូវអធិដ្ឋានទាំង៥តាមបំណងរបស់ព្រះភគវ័តចុះ ។

តើអធិដ្ឋានទាំង៥នោះដូចម្តេចខ្លះ .[១]

៥- ១- ព្រះភគវាបរមគ្រូ ពេលទ្រង់បើងលើព្រះគ្រែទ្រាបន្ទំមហាបរិនិព្វានទ្រង់អធិដ្ឋានថា បើពេលអសោកមហារាជយាងទៅសាកនូវដែមកព្រះមហាពោធិព្រឹក្សទៅប្រតិស្ឋានក្នុងមហាពោធិស្ឋាននាលង្កាទ្វីប ពេលនោះសូមដែមកមហាពោធិព្រឹក្សខាងត្បូងដាច់ឯងមកប្រតិស្ឋានក្នុងផើងមាសចុះ ។

២- ទ្រង់អធិដ្ឋានថា បើព្រះមហាពោធិព្រឹក្សនេះប្រតិស្ឋានលើចង់ទៅក្នុងទីនោះហើយ សូមអោយភ្លៀង ហិមវារាពកៈបង្អុរចុះកុំដាច់ ។

www.budinst.gov.kh www.elibraryofcambodia.org

៣- ទ្រង់អធិដ្ឋានថា ក្នុងថ្ងៃទី៧ សូមអោយតេណ្ណរង្សីយាងចុះ ចាកថ្ងៃទីនតិមវិណ្ណាហក: មកប្រតិស្ឋានក្នុងផើងមាសហើយបញ្ចាញ ស្លឹក និងផ្លែទាំងឡាយយ៉ាងរយោងយោង ។

៤- ទ្រង់អធិដ្ឋានថា ក្នុងវត្តថ្ងៃរាម សូមព្រះអដ្ឋកធាតុខាង ស្ដាំផ្ញើមកបញ្ញាដិហារ្យ ក្នុងថ្ងៃដែលប្រតិស្ឋានក្នុងព្រះចេតិយនូច ៗ

៥- ទ្រង់អធិដ្ឋានថា ព្រះសារីរិកធាតុរបស់អញតថាគតចំនួន មួយទោណក្នុងលង្កាទ្វីបឯណោះ សូមការនាំយកនូវពុទ្ធភេទ ក្នុងពេលដែលប្រតិស្ឋានក្នុងមហាចេតិយនេះហើយទោះទៅលើវិហារសាន ភាល័យស្ដេចនូវយមកបញ្ញាដិហារ្យកុំបីខាន ៗ

ព្រះរាជាល្អះបានស្ដាប់ហើយ ទ្រង់មានព្រះហឫទ័យជ្រះថ្លាណាស់ហើយក៏ទ្រង់អោយចាត់ការធ្វើផ្លូវ ពីក្រុងបាតលិបុត្រយ៉ាងល្អាតរហូតដល់ព្រះមហាពោធិព្រឹក្ស ៗ

ឯព្រះវិស្សុកម្មទេវបុត្រ ក៏មកទទួលការធ្វើជាជាងសាងផើងមាសចំនួនកំពស់៥ហត្ថ ទទឹង៣ ហត្ថកម្រាស់ ៨ អង្គុលី ៗ

ព្រះរាជាព្រមទាំងសេនាមាត្យ និង ភ្លេងដូរ្យតន្ត្រី ព្រមទាំងអរិយសង្ឃច្រើនឥតគណនា បានយាង និមន្តនិងអញ្ជើញនោះទៅកាន់ទីជិតព្រះមហាពោធិព្រឹក្ស :

គេរៀបប្រចុកក្សោ ពាជុំគេប្រគុំដូរ្យតន្ត្រី គេថ្វាយគ្រឿងគន្ធពិដោរគេដាក់ផើងមាសក្រោមមែកនោះ រួចព្រះរាជាទ្រង់ឈរលើកែនះ ហើយយកជក់មាសគូសជាលក្ខណ៍ដីមែកមហាពោធិព្រឹក្សដោយមនោសិលាជាតិ រួចគេធ្វើសច្ចកិរិយាបួងសួងសូមអារាធនាមែកព្រះមហាពោធិព្រឹក្ស ខាងស្ដាំទៅប្រតិស្ឋានក្នុងលង្កាទ្វីប ពេលនោះគេឃើញមែកព្រះមហាពោធិព្រឹក្សខាងស្ដាំដាច់ឯងស្លាយមកប្រតិស្ឋានលើផើងមាស ៗ

www.budinst.gov.kh www.elibraryofcambodia.org

គេធ្វើបុណ្យអភិសេកក្នុងទីនោះ អស់ថ្ងៃ ៧ ទើបគេដង្ហែមក កាន់ក្រុងបាតលិបុត្រ ដំណើរទុកនេះ ។ លុះព្រះសង្ឃមិត្តាថេរី ត្រូវនិមន្តទៅលង្កាទ្វីប គេក៏ថ្វាយព្រះមហាពោធិព្រឹក្សនេះដល់ ព្រះសង្ឃមិត្តាថេរី ដង្ហែទៅកាន់កំពង់សមុទ្រអស់លោកក៏បានរៀប ពិធីបូជា នូវ មហារាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ដល់ព្រះមហា ពោធិព្រឹក្សនេះ នាមាត់សមុទ្រនោះអស់ ៧ ថ្ងៃទៀត ។

គេឃើញអស់លោកចុះក្នុងទឹកសមុទ្រត្រឹមកទូលនឹងព្រះមហាពោធិ ព្រឹក្សដាក់លើនាវា ។

គេឃើញព្រះសង្ឃមិត្តាថេរី ព្រមទាំងភិក្ខុនីជាព្រះអរហន្ត ឯទៀតចំនួន ៥០០ អង្គ គង់លើនាវា ។

គេឃើញតែក្រុមផ្កាបុប្ផផ្សេងៗ អណ្តែតដេរដាសពេញផ្ទៃ សមុទ្រ ឥតមានពពុះខ្យល់អ្វីទេ មានតែពលនាពួកនាគ មកសូមការ អនុញ្ញាតពីព្រះសង្ឃមិត្តាថេរី ដោយផ្អាកដំណើរនេះចំនួន ៧ ថ្ងៃ ដោយពួកគេបានបូជាផងបុណ្ណោះ ។

រួចនាវានេះបន្តដំណើរទៀតដល់កំពង់ផែ ជម្ពូកោឡប្ប តែម្តង

ដឹងក្នុងលង្កាទ្វីបឯណោះវិញ តាមបញ្ញាសុមនសាមណេរ និង ដោយអានុភាពរបស់ព្រះមហិន្ទថេរ និង ព្រះរាជាផងដែរក្រុង ទាំងមូលមានផ្លូវ និង មហាប្រជាពុទ្ធសាសនិកមានសោភណភាព និង អឹកធឹកច្រើនឥតគណនាឡើយ ដែលរង់ចាំទទួលនោះ ។

ក្នុងថ្ងៃ ១ កើតខែ មិគសិរ គេឃើញព្រះទេវានម្បិយតិស្ស ចុះក្នុងទឹកសមុទ្រត្រឹមក ចាំទទួលទូលព្រះមហាពោធិព្រឹក្សនោះ រួចគេរៀបអភិសេក នៅនាមាត់សមុទ្រនោះអស់ ៣ ថ្ងៃ

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងថ្ងៃទី៤ ទើបគេដង្ហែទៅកាន់ក្រុងអនុរាធបុរី ។ គេដង្ហែព្រះមហាពោធិព្រឹក្សនេះតាមទ្វារខាងជើង កាត់តាមកណ្តាលក្រុងអនុរាធបុរី ចេញទៅតាមទ្វារខាងត្បូង រួចចេញពីទិសខាងត្បូងព្រះពោធិព្រឹក្ស ព្រះពុទ្ធពារអង្គស្ថិតនៅទីណា គេយកព្រះមហាពោធិព្រឹក្សនេះ ទៅប្រតិស្ឋានទុកក្នុងមហាមេឃវ័នឧយ្យាន នាទីនោះក្នុងថ្ងៃពេញបូណ៌មី ខែ មិគសិរ ។

ផ្កាការអស្ចារ្យណាស់ ព្រះមហាពោធិព្រឹក្សនេះ គ្រាន់តែដាក់ដាំផុតពីព្រះហស្ត ពីទេវស្ថាម ក៏ផុះឡើងមានកំពស់ ៨០ ហត្ថ ហើយអណ្តែតទៅលើមេឃបញ្ចេញនូវពណ្ណរង្សី ៦ ពណ៌គ្របលង្កាទ្វីបទាំងមូលភ្លឺទល់ព្រហ្មលោកឯណោះ ។

ផា: មានបុរសចំនួន ១០០០០រូប ជ្រះថ្លានឹងមហាពោធិប្បាដិហារ្យនោះ តាំងខ្ជាប់នូវអនុបុព្វីបសន្នាបួសសម្រេចព្រះអរហត្តទាំងអស់ ។ មហាមេឃស្រទំដាប់ពាំទ័ព្វ មានតែពន្លឺពណ្ណរង្សីប៉ុណ្ណោះ ។ ក្នុងថ្ងៃទីពិព្រះមហាពោធិព្រឹក្សនេះក៏បញ្ចេញនូវ ផើម ផែក ស្លឹក និង ផ្លែ ៥ ទៀតផង ។

គ្រានោះព្រះមហិន្ទត្ថេរ ព្រះសង្ឃមិត្តាថេរី ព្រះរាជាព្រមទាំងបរិវារ និង ពួកប្រជាធិករជាច្រើនឥតគណនា ដែលនិមន្ត យាង និងអញ្ជើញទៅកាន់ទីនោះ គេកំពុងតែទស្សនាដោយការអស្ចារ្យ ក៏ស្រាប់តែផ្លែមួយជ្រុះចាកមែកធ្លាក់មកប្រតិស្ឋានក្នុងព្រះហស្តព្រះមហិន្ទត្ថេរ ៗ លោកហុចទៅថ្វាយព្រះរាជា អោយយកទៅដាំ ដាំភ្លាមក៏ផុះភ្លាម ហើយមានចំនួន ៨ ផុះកំពស់ចំនួន ៤ ហត្ថភ្លាមដែរ ។

លុះប្រតិស្ឋានព្រះមហាពោធិព្រឹក្សរួចហើយ គេឃើញអនុឡាទេវី និង រាជកញ្ញាព្រមទាំងកញ្ញាអ្នកបម្រើឯទៀតចំនួន ១០០០រូប បួសក្នុងសំណាក់ព្រះសង្ឃមិត្តាថេរី មិនយូរប៉ុន្មាន ក៏បាន លុះព្រះអរហត្តទាំងអស់ ។

ឯអរិដ្ឋអាមាត្យ ជាក្មួយស្តេច ព្រមទាំងបុរសចំនួន៥០០រូប ក៏

www.budhist.gov.kh www.elibraryofcambodia.org

បួសក្នុងសំណាក់ព្រះថេរៈ បានសម្រេចអរហត្តទាំងអស់ដែរ ។

ក្រែងមានការវិវត្តន៍នៃពុទ្ធសាសនានាអនាគត នោះទើបមហិន្ទត្ថេរនិងស្តេច បញ្ជាឲ្យឆ្លាក់សិលាចារឹកទុកក្បែរថូបារាមចេតិយនោះថា ក្រែងឲ្យព្រះនត្តានាមទុដ្ឋគាមណីអភ័យ ជាចៅស្តេចទេវានម្បិយតិស្សៈ ដែលនឹងសោយរាជ្យក្នុងលង្កានាអនាគត នោះកសាងថែមនូវព្រះស្តូបក្នុងប្រទេសនេះទៀតផង ។

ដោយហេតុបំណងឲ្យបួសពុទ្ធសាសនា ដុះជាប់ក្នុងលង្កានេះ ទើបព្រះរាជាចាត់ឲ្យសាងមហ្លោបត្រង់បរិវេណ របស់មេឃវណ្ណាឧយាន ដើម្បីសណ្ឋាយនាវិន័យនិងធម៌នាវត្តថូបារាមនោះ ។

ឯការកសងស្រែទិប្បាតចំនួន៦៨·១០០រូបមានព្រះមហិន្ទ-ត្ថេរជាប្រធាន មហាអរិដ្ឋត្ថេរអ្នកសំដែងវិន័យ, ព្រះចៅទេវា-នម្បិយតិស្សៈអ្នកឧបត្ថម្ភ ព្រោះពួកការប្រតិស្ឋាន(១)ពុទ្ធសាសនា

---

(១) ជាៈ ១២ ឆ្នាំអំពីការប្រតិស្ឋានពុទ្ធសាសនាជាដំបូងក្នុងលង្កានេះ ទៅព្រះនាងអសន្ធិមិត្តាទ្រង់ទិវង្គត ។ ជាៈ ៤ ឆ្នាំអំពីទិវង្គតនៃព្រះនាងអសន្ធិមិត្តា

ផ្លូង ---

www.budinst.gov.kh www.elibraryofcambodia.org

ចុះទុកក្នុងគម្ពីរស្លឹករឹតជាសក្ខីភាពមក ។ ប្រជុំធ្វើក្នុងវត្តអភយគិរី មលយជនបទ លង្កាទ្វីបដោយមានព្រះបាទវដ្តគាមណីអភ័យជាអ្នកឧបត្ថម្ភ ១ ឆ្នាំទើបចប់ ។

## ៥- អ្នកចម្លងគម្ពីរពីលង្កាមកវិញ

លុះ ព.ស. ៩៥៦ ឆ្នាំ ក្នុងរជ្ជកាលព្រះបាទមហានាម នាលង្កាទ្វីបនេះ ។

ឯក្នុងជម្ពូទ្វីបជិតពោធិគយា មានមាណពម្នាក់ឈ្មោះឃោសកុមារជាកូនព្រាហ្មណ៍ កុមារនេះរៀនចប់ត្រៃវេទទាំង ៣ ផង ។

កុមារតែងដើរសួរបញ្ហាផ្សេងៗ តែគ្មានមនុស្សណាឆ្លើយរួចឡើយ ។ លុះទៅដល់វត្តមួយ មានភិក្ខុចំនួនជាង ១០០រូប មានព្រះអរហន្តនាម រេវតៈត្រូវជាប្រធាន មាណពនោះក៏ចូលទៅសួរបញ្ហា ព្រះអរហន្តអង្គនោះឆ្លើយរួចទាំងអស់, រួចលោកថា: មាណពឯងសួរអាត្មាច្រើនណាស់

www.budinst.gov.kh www.elibraryofcambodia.org

~~ក្រោយ~~ ហើយ ឥឡូវនេះអាត្មាសូមសូត្រម្ដងវិញ ។

ព្រះថេរៈស្ងប់ក្នុងចិត្តយកៈ មាណពនោះឥតល្ងើយរួចឡើយ; ទើបសុំបួស លុះព្រះថេរៈបំបួសរួច ភិក្ខុថ្មីនេះក៏បានរៀននូវព្រះត្រៃបិដកអំពីសំណាក់គ្រូ ចេះចាំស្ទាត់មាត់ទាំងហើយបាននាមថា: ពុទ្ធឃោសភិក្ខុឯង ។

ពុទ្ធឃោសភិក្ខុកាលនៅក្នុងនោះ ប្រុងទិនធ្វើគម្ពីរញាណោទ័យ ព្រមទាំងគម្ពីរអដ្ឋសាលិនី និងអដ្ឋកថាបរិត្តផងៗ

ព្រះរេវតត្ថេរជាគ្រូមានថេរដីកាថា ម្នាលពុទ្ធឃោសភិក្ខុ! ក្នុងជម្ពូទ្វីបនេះព្រះត្រៃបិដកមានតែបាលីសុទ្ធ ឯអដ្ឋកថានិងថេរវាទមិនមានទេ មានតែនៅក្នុងសីហលភាសាហើយនៅឯសីហលទ្វីបឯណោះផង; ដូច្នេះឯងគួរទៅកាន់សីហលទ្វីប ពិនិត្យមើលឲ្យសព្វគ្រប់ហើយ ប្រែចម្លងមកជាមគធភាសាវិញ ទើបសម្រេចប្រយោជន៍ដល់មនុស្សលោកទាំងអស់បាន ។

លុះឮហើយក៏មានសេចក្ដីត្រេកអរណាស់ ទើបថ្វាយ

www.budinst.gov.kh www.elibraryofcambodia.org

បង្គំលាគ្រូនិងព្រះសង្ឃ ទៅកំពង់សមុទ្រឡើងនាវាទៅតាម ដល់កណ្ដាលសមុទ្របានជួបនឹងព្រះពុទ្ធទត្តត្ថេរដែរ, បានសន្ទនាគ្នារួចហើយ ក៏បន្ដដំណើរទៅលង្កាទ្វីបតែម្ដង ។

ពុទ្ធឃោសភិក្ខុបានទៅជួបព្រះសង្ឃ ក្នុងមហាវិហារ ទើបហួសទៅជួបព្រះសង្ឃបាលត្ថេរ ក្នុងមហាបធានឃរៈទៀត, ហើយបានទៅស្ដាប់នូវអដ្ឋកថាជាសីហលភាសានិងថេរវាទទៀតផង ។

ដោយពុទ្ធឃោសភិក្ខុបានឃើញនូវបាលីព្រះត្រៃបិដកនិងអដ្ឋកថានោះ ក៏ចាប់ប្រែបានជាគម្ពីរវិសុទ្ធិមគ្គមួយក្បាល ។ រួចយកទៅបង្ហាញព្រះសង្ឃ ។ ឃើញនូវសមត្ថភាពដ៏អស្ចារ្យបែបនេះ ក៏ប្រគល់នូវបាលីព្រះត្រៃបិដក និងអដ្ឋកថាជាសីហលភាសានោះឲ្យមកទាំងអស់, ពុទ្ធឃោសភិក្ខុយកគម្ពីរទាំងនេះទៅធ្វើនិងប្រែក្នុងប្រាសាទមួយឈ្មោះបធានឃរៈ នាភាគទក្សិណនៃមហាវិហារ ។

តាមពិតមាននេះថា ៖ អដ្ឋកថាដែលព្រះសង្ឃលង្កាទ្វីប

www.budinst.gov.kh www.elibraryofcambodia.org

បានះមនាហើយនោះមានពីរបែបគឺៈ ១ អដ្ឋកថាដែលទ្បើង កាន់មហាសង្គាយនា ហើយដែលព្រះមហិន្ទត្ថេរក្រាន់ការធ្វើ ជាសីហលភាសានោះ ហៅថាមហាអដ្ឋកថា; ២–អដ្ឋកថា ដែលព្រះសង្ឃលង្កា ប្រជុំគ្នាធ្វើលើក្បូនឬផែនោះ ហៅថាបច្ចរិយដ្ឋកថា; ៣ អដ្ឋកថាដែលព្រះសង្ឃលង្កា ប្រជុំគ្នាធ្វើ ក្នុងកុរុន្ទិវេឡុវិហារនោះ ហៅថាកុរុន្ទដ្ឋកថា ។

ឯពួកដែលព្រះថេរៈចាស់ទុំជាខ្មុនទាំងឡាយ បាន រចនាតាមលំនាំទ្វាល់នោះ ហៅថាថេរវាទ ។

ពុទ្ធឃោសភិក្ខុ បានប្រែចម្លងកុរុន្ទដ្ឋកថា ពីសីហល-ភាសាមកជាមគធភាសាវិញនោះ ធ្វើជាអដ្ឋកថាវិន័យ ។

ប្រែចម្លងមហាអដ្ឋកថា ពីសីហលភាសាមកជាមគធ ភាសាវិញនោះ រចនាធ្វើជាអដ្ឋកថាព្រះសូត្រ ។

ហើយប្រែចម្លងបច្ចរិយដ្ឋកថា ពីសីហលភាសាមក ជាមគធភាសាវិញនោះ រចនាធ្វើជាអដ្ឋកថាអភិធម្ម ។

ការប្រែចម្លងនេះខុសគ្នាពីចប់ ៗ រួចហើយក៏ថ្វាយបង្គំ



www.budinst.gov.kh www.elibraryofcambodia.org

(នេះសឲ្យឃើញថា៖ ព្រះត្រៃបិដកនិងអដ្ឋកថា ដែលបានកត់ជាតួអក្សរ ផ្សាយចូលមកក្នុងប្រទេសសុវណ្ណភូមិ គឺភូមានិងកម្ពុជា ក្នុងសម័យនោះឯង) ។

---

១.០០០ នារវាងកាលស្តេចសិរីកិត្តិរាជ រដ្ឋខ្មែរកើតសឹកសង្គ្រាម ពុទ្ធសាសនាក៏ចេះតែថយចុះ គេក៏និមន្តព្រះកែវមរកតនេះទៅប្រតិស្ឋានក្នុងវត្តខេមរតិរ៉ៈមហាវិហារខាងលង្កាទ្វីប ។ លុះព.ស.១៥៦០ ព្រះបាទធម្មាសុរក្ខស្តេចភូមាទៅចម្លងគម្ពីរពីលង្កា សុំព្រះពុទ្ធរូបកែវមរកតនេះដាក់សំពៅមក ដោយបុញ្ញលាភព្រះពុទ្ធរូបអង្គនេះ ក៏ទ្រង់គង់សំពៅនិមន្តចូលមកនគរកម្ពុជាវិញ ។

( ប្រវត្តិពុទ្ធសាសនាចប់ )

www.budinst.gov.kh www.elibraryofcambodia.org

ប្រវត្តិរបស់ព្រះពុទ្ធអង្គនាភទ្ទកប្បនេះ (មានតទៅ)

១- គោត្រ : ព្រះកកុសន្ធោ ព្រះកោនាគមនោ ព្រះកស្សបោ ទាំង៣អង្គនេះ ជាកស្សបគោត្រ ឯព្រះសមណគោតម ជាគោតមគោត្រ

២- ជាតិ : ព្រះកកុសន្ធោ ព្រះកោនាគមនោ ព្រះកស្សបោទាំង ៣ អង្គនេះ ជាជាតិព្រាហ្មណ៍ ឯព្រះសមណគោតមជាខត្តិយជាតិ ។

៣- ចេញទ្រង់ព្រះផនួស ព្រះកកុសន្ធោ គង់រថទឹមសេះអាជានេយ្យ ព្រះកោនាគមនោគង់ដំរី ព្រះកស្សបោ គង់ប្រាសាទ ឯព្រះសមណគោតមគង់ កណ្ឋក អាជានេយ្យ ។

៤- ធ្វើទុក្ករកម្ម : ព្រះកកុសន្ធោ ១០ ខែ ព្រះកោនាគមនោ ៦ខែ ព្រះកស្សបោចំនួន ៧ ថ្ងៃ ឯព្រះសមណគោតមចំនួន ៦ ឆ្នាំ ។

៥- សាវកសន្និបាត : ព្រះកកុសន្ធោ មានសាវកសន្និបាតតែម្តង មានអរហន្តភិក្ខុចំនួន ៤០០០០ អង្គមកជួបសន្និបាត ដ៏ព្រះកោនាគមនោ មានសាវកសន្និបាតមួយដងដែរ មានអរហន្តភិក្ខុចំនួន ៣០០០០ អង្គមកជួបសន្និបាត ឯព្រះកស្សបោ ក៏ មានសាវកសន្និបាតមួយដងដែរ និង មានអរហន្តភិក្ខុចំនួន ២០០០០ អង្គមកជួបសន្និបាត ឯព្រះសមណគោតម ក៏ មានសាវកសន្និបាតមួយដងដែរ ហើយមានអរហន្តភិក្ខុចំនួន ១២៥០ អង្គ មកជួបសន្និបាត ។

៦- គូនៃអគ្គសាវក : ព្រះកកុសន្ធោ មានវិធូរៈអរហន្តជាអគ្គសាវក ទី ១ និង សញ្ជីវអរហន្តសាវកទី ២ ដ៏ព្រះកោនាគមនោមាន ភិយ្យោសៈអរហន្តជាអគ្គសាវក ទី ១ ឧត្តរៈអរហន្តជាអគ្គសាវកទី ២ ដ៏ ព្រះកស្សបោ មានតិស្សៈអរហន្តជាអគ្គសាវកទី ១

www.budinst.gov.kh www.elibraryofcambodia.org

ការទ្រាជ: អរហន្តជាអគ្គសាវកទី ២ ឯព្រះសមណគោតម មានព្រះសារីបុត្តត្ថេរ ជាអគ្គសាវកទី១ ព្រះមហាមោគ្គល្លានត្ថេរ ជាអគ្គសាវកទី ២ ។

៧- ឧបដ្ឋាកភិក្ខុ: ព្រះកកុសន្ធៈ មានវុឌ្ឍិជៈភិក្ខុជាពុទ្ធុបដ្ឋាក ព្រះកោនាគមនៈ មានសោត្ថិជៈភិក្ខុជាពុទ្ធុបដ្ឋាក ព្រះកស្សបៈ មានសព្វមិត្តភិក្ខុជាពុទ្ធុបដ្ឋាក ឯព្រះសមណគោតមមានអានន្ទត្ថេរជាពុទ្ធុបដ្ឋាក ។

៨- ព្រះជន្មាយុ: ព្រះកកុសន្ធៈ ៤០០០០ ឆ្នាំ ព្រះកោនាគមនៈ ៣០០០០ ឆ្នាំ ព្រះកស្សបៈ ២០០០០ ឆ្នាំ ឯព្រះសមណគោតម ៨០ ឆ្នាំគត់ ។

៩- ព្រះមាតាបិតា: អគ្គិទត្តព្រាហ្មណ៍ និង នាងវិសាខាព្រាហ្មណី ជាព្រះមាតាបិតា របស់ព្រះកកុសន្ធៈ ក្នុងនគរខេមវតី ព្រះរាជាឈ្មោះ ខេមរាជ យញ្ញទត្តព្រាហ្មណ៍ និងនាងឧត្តរាព្រាហ្មណី ជាព្រះមាតាបិតារបស់ព្រះកោនាគមនៈក្នុងនគរសោភៈ ស្ដេចឈ្មោះសោភរាជ ព្រហ្មទត្តព្រាហ្មណ៍ និង នាងធនវតីព្រាហ្មណី ជាព្រះមាតាបិតារបស់ព្រះកស្សបៈក្នុងនគរពារាណសី ព្រះរាជាឈ្មោះ កិ កីរាជ សុទ្ធោទនៈមហារាជ និង ព្រះរាជទេវីឈ្មោះសិរិមហាមាយា ជាព្រះមាតា

www.budinst.gov.kh www.elibraryofcambodia.org

ជាព្រះមាតាបិតារបស់ព្រះសមណគោតម

ក្នុងនគរកបិលវត្ថុ ។

១០- ព្រះទេពីត្រឹមត្រូវ : ទើបព្រះជាមហាទេពីត្រឹមត្រូវ

របស់ព្រះកោនាគមនា ទើមទីព្រះជាមហាទេពីត្រឹមត្រូវ

កក្កុសន្ធ ... ព្រះកោនាគមន

របស់ព្រះកស្សប ទើមភស្សត្រូវ ជាមហាទេពីត្រឹមត្រូវ

របស់ព្រះសមណគោតម ។

១១- អធិការ : ព្រះកក្កុសន្ធ ព្រះកោនាគមនា ព្រះកស្សប

ទេព្វជាសទ្ធាធិក ។ ឯព្រះសមណគោតមជាបញ្ញាធិក ។

១២- ពុទ្ធជាយា " កវីនស្សារទេព្រួង " : អបរូទោធិធី

ជាព្រះជាយាព្រះកក្កុសន្ធ និង បុត្រមួយឈ្មោះ អនុត្តរៈ ;

សុភាវតី ជា ជាយាព្រះកោនាគមនា និង បុត្រមួយ

ឈ្មោះ សត្ថវាហ, សុនន្ទាជា ជាយាព្រះកស្សប និង បុត្រមួយ

ឈ្មោះ វិជិតសេនា, ព្រះរាជកញ្ញានាម យសោធរា ពិម្ពា

ជាអគ្គមហេសី របស់ព្រះ សិទ្ធត្ថ មានរាជបុត្រមួយនាម រាហុល ។

១៣- បល្ល័ង្ក កំពស់ និង រស្មី : ព្រះកក្កុសន្ធមានព្រះបល្ល័ង្ក

កំពស់ ២៦ ហត្ថ កំពស់ ព្រះអង្គ ៤០ ហត្ថ មានព្រះរស្មីផ្សាយ ១០ យោជន៍

... ព្រះកោនាគមនា មានព្រះបល្ល័ង្កកំពស់

២០ ហត្ថ កំពស់ព្រះអង្គ ៣០ ហត្ថ មានរស្មីផ្សាយ—

www.budinst.gov.kh www.elibraryofcambodia.org

ចេញទាប់មិនបាន ព្រះកស្សបៈ មានព្រះបល្ល័ង្ក១៥ហត្ថ កំពស់ព្រះអង្គ២០ហត្ថ មានព្រះរស្មីផ្សាយចេញរាប់មិនបាន - ព្រះសមណគោតម មានព្រះបល្ល័ង្ក ១៤ ហត្ថកំពស់ព្រះអង្គ១៨ហត្ថ មានព្រះរស្មីផ្សាយចេញ ពួយក្បាលជុំវិញទាំងពីរខាង ។

ដោយឡែកអនាគត នឹង មានព្រះសិរអារ្យមេត្រីត្រាស់ នាភទ្ទកប្បនេះដែរ មានព្រះជន្ម ៨០០០០ ឆ្នាំ ដើមឈ្មឹង ជាពោធិព្រឹក្សទ្រង់ បល្ល័ង្ក ៥៣ ហត្ថកំពស់ព្រះអង្គ ៨០ ហត្ថ ទុក្ករកម្ម ៧ ថ្ងៃ គង់ប្រាសាទចេញបួស មានព្រះរស្មីផ្សាយចេញ រាប់មិនបាន ព្រះអង្គជាព្រាហ្មណ៍ជាតិ ព្រះបិតានាមសុព្រហ្ម ព្រាហ្មណ៍ ព្រះមាតានាមព្រហ្មវតី ព្រាហ្មណី អគ្គមហេសី នាម ចន្ទមុខី បុត្រនាម ព្រហ្ម វឌ្ឍន៍ នគរឈ្មោះ កេតុមតី កេតុមារាជ ព្រះជាវីរិយាធិក ។

ចាក អាគតដ្ឋាន នានា ភាគច្រើនមហាបទានសុត្តវណ្ណនា

www.budinst.gov.kh www.elibraryofcambodia.org

# បកិណ្ណកកថា

អនិសម្ម កតំ កម្មំ

អនវត្ថាយ ចិន្តិតំ

ភេសជ្ជស្សេវ វេមត្តា

វិបាកោ ហោតិ បាបកោ ។

និសម្ម ច កតំ កម្មំ

សម្មាវត្ថាយ ចិន្តិតំ

ភេសជ្ជស្សេវ សម្បត្តិ

វិបាកោ ហោតិ ភទ្រកោ ។

កិច្ចការណាដែលមិនបានពិចារណាហើយធ្វើ, និងដែលមិនបានប្រៀបធៀបថ្លឹងគិតឲ្យសព្វគ្រប់ជុំវិញសិនទេ, នោះគេគង់នឹងទទួលផលអាក្រក់មិនខាន ដូចគុណវិបត្តិនៃថ្នាំពេទ្យ ។

បើកិច្ចការណា ដែលគេបានពិចារណាហើយសឹមធ្វើ, និងដែលបានប្រៀបធៀបថ្លឹងគិតត្រឹមត្រូវជាក់ល័ក្ខហើយនោះគេ

www.budinst.gov.kh www.elibraryofcambodia.org

រមែងបានទទួលនូវផលល្អជាងដាច់ខាត ដូចគុណសម្បត្តិនៃថ្នាំពេទ្យ ។

អលសោ គិហី កាមភោគី ន សាធុ,
អសញ្ញតោ បព្វជិតោ ន សាធុ,
រាជា ន សាធុ អនិសម្មការី,
យោ បណ្ឌិតោ កោធនោ តំ ន សាធុ ។

គ្រហស្ថអ្នកបរិភោគកាមខ្ជិលច្រអូសមិនល្អទេ;
អ្នកបួសមិនសង្រួមកាយវាចាចិត្តមិនល្អទេ,
ស្តេចឥតស្រាវជ្រាវមិនមានការពិចារណាមិនល្អទេ,
បណ្ឌិតណាអ្នកក្រេវក្រោធ នោះមិនល្អទេ ។

(សោមនស្សជាតកវីសតិនិបាត)

ន សោ រាជា យោ អជេយ្យំ ជិនាតិ,
ន សោ សខា យោ សខារំ ជិនាតិ,
ន សា ភរិយា យា បតិនោ វិភេតិ,
ន តេ បុត្តា យេ ន ភរន្តិ ជិណ្ណំ ។

www.budinst.gov.kh www.elibraryofcambodia.org

ដីដែនណាចង់ឈ្មោះមាតាបិតា ជននោះមិនឈ្មោះថា ស្តេចទេ,

មិត្រសំឡាញ់ណាចង់ឈ្មោះមិត្រសំឡាញ់ នោះមិនឈ្មោះ ថាមិត្រទេ,

បុរសស្ត្រីណាមិនគោរពខ្លាចចិត្តប្តីប្រពន្ធ នោះមិនឈ្មោះ ថាភរិយាស្វាមីទេ,

បុត្រធីតាណាមិនចិញ្ចឹមមាតាបិតាចាស់ នោះមិនឈ្មោះ ថាបុត្រធីតាទេ ។

ន សា សភា យត្ថ ន សន្តិ សន្តោ,
ន តេ សន្តោ យេ ន ភណន្តិ ធម្មំ,
រាគញ្ច ទោសញ្ច បហាយ មោហំ
ធម្មំ ភណន្តាយេវ ភវន្តិ សន្តោ ។

សប្បុរសជនមិនមានក្នុងសភាណា ទីប្រជុំនោះមិនឈ្មោះ ថាសភាទេ,.

ជនណាមិនពោលធម៌ជននោះមិនឈ្មោះថាសប្បុរសទេ,

www.budinst.gov.kh www.elibraryofcambodia.org

លុះតែលះបង់រាគៈ ទោសៈ និង មោហៈ ហើយមាន

តែធម៌សុទ្ធ ទើបឈ្មោះជាសប្បុរស ។

(មហាសុតសោមជាតកអសីតិនិបាត)

សុទុល្លភិត្ថី បុរិសស្ស យា ហិតា,

ភត្តិត្ថិយា ទុល្លភោ យោ ហិតោ ច ។

ស្ត្រីជាភរិយាណាប្រព្រឹត្តល្អដល់បុរស ស្ត្រីនោះគេមិនងាយរកបានទេ,

បុរសជាប្តីណាប្រព្រឹត្តល្អដល់ស្ត្រី បុរសនោះក៏គេមិនងាយរកបានដែរ ។

(សម្ពុលាជាតកតឹសតិនិបាត)

ទុល្លភោ ហិ មនុស្សត្តំ,

សទ្ធា ច ធន ទុល្លភា,

ទុល្លភោ ជិនសទ្ធម្មោ,

ទេសកោ ចាបិ ទុល្លភោ

ភាពដែលពេញជាមនុស្ស គេរកបានក្រណាស់,

www.budinst.gov.kh www.elibraryofcambodia.org

ការព្រៀងសមហេតុ-ផល ក៏រកបានក្រណាស់,

ធម៌របស់អ្នកឈ្នះកិលេសតណ្ហាគេមិនងាយបានជួបទេ,

អ្នកបង្អុលធម៌ពិតក៏មិនងាយជួបប្រទះដែរ ។

( មហាវង្ស )

ឆត្តា នទី អទោទកា, នគ្គំ រដ្ឋំ អរាជិកំ

ឥត្ថី បិ វិធវា នគ្គា យស្សាបិ ទស ភាតរោ ។

ស្ទឹងមិនមានទឹកឈ្មោះថាស្ទឹងអាក្រាត,

រដ្ឋមិនមានអ្នករាជការឈ្មោះថារដ្ឋអាក្រាត,

ស្ត្រីណាមានបងប្អូនសម្បូរ១០នាក់តែមិនមានប្តី ប្ត នៅ

ព្រៅ ស្ត្រីនោះឈ្មោះថាអាក្រាត ។

( ឧច្ចង្គជាតកឯកនិបាត )

គោណំ ធេនុញ្ញ យានញ្ញ

ភរិយំ ញាតិកុលេ ន វាសយេ ។

(ទ្រព្យទាំង៤គឺ:) គោពេញប្រើ១, មេគោមានទឹកដោះ១,

រទេះយានល្អ១, ភរិយាមានរូប១, មិនត្រូវឲ្យនៅឆ្ងាយពីខ្លួន

www.budinst.gov.kh www.elibraryofcambodia.org

ឬ ឲ្យនៅឆ្ងាយពីក្នុងត្រកូលញាតិខ្លួនទេ ។

( កុណាលជាតក អសីតិនិបាត )

យស្ស រុក្ខស្ស ឆាយាយ
និសីទេយ្យ សយេយ្យ វា,
ន តស្ស សាខំ ភញ្ជេយ្យ,
មិត្តទុព្ភោ ហិ បាបកោ ។

មនុស្សយើងបើជ្រកក្រោមម្លប់ឈើណា ,
មិនត្រូវកាប់មែកឈើនោះចោលទេ ,
ព្រោះវាក្លាយជាមនុស្សទ្រុះមិត្រដ៏អាក្រក់ ។

( មហាពោធិជាតកបញ្ញាសនិបាត )

យស្សេតេ ចតុរោ ធម្មា វានរិន្ទ យថា តវ
សច្ចំ ធម្មោ ធិតិ ចាគោ ទិដ្ឋំ សោ អតិវត្តតិ ។

ម្នាលស្តេចវានរ ! ជនណាមានគុណធម៌ទាំង៤នេះគឺ .
វចីសច្ចៈ (ពាក្យពិត) ១, ធម្មៈ (វិចារណញ្ញាណ) ១,
ធិតិៈ (ព្យាយាមមិនបន្ថយ) ១, ចាគៈ (តស៊ូសុខចិត្ត

www.budinst.gov.kh www.elibraryofcambodia.org

សរត ) ១.
ឈរដ៏វិត)

ជននោះរមែងដកខ្លួនផុតនូវគ្រោះថ្នាក់ ដូចអ្នកមិនមាន ។

(ភិនវិន្ទជាតកឯកនិបាត)

អារោគ្យមិច្ឆេ បរមញ្ច លាភំ
សីលញ្ច ពុទ្ធានុមតំ សុតញ្ច
ធម្មានុវត្តី ច អលីនតា ច
អត្ថស្ស ទ្វារា បមុខា ឆ ឯតេ ។

មនុស្សត្រូវប្រាថ្នានូវបរមលាភគឺភាពដែលមិនមានរោគ១, នូវអាចារៈសីលឬលោកចារិត្តសីល១, នូវឱវាទរបស់បណ្ឌិត១, នូវការស្តាប់ឲ្យបានច្រើន១, នូវការអនុវត្តន៍តាមសុចរិតធម៌១, នូវភាពនៃចិត្តក្លាហានមិនរួញរា១, គុណធម៌ទាំង៦នេះជាប្រមុខឬជាទ្វារសំរាប់ហូរចូលមកនៃអត្ថប្រយោជន៍(ទាំង៣)។

(អត្ថស្សទ្វារជាតកឯកនិបាត)

កាលពុទ្ធសាសនាមិនទាន់កើតនោះ ភូមិភាគនៃមជ្ឈិម

www.budinst.gov.kh www.elibraryofcambodia.org

ប្រទេស មានរបៀបរបបតាមលទ្ធិព្រាហ្មណ៍សេរីភេទ

តាំងប្រជាជនសោត ក៏មិនទាន់មានសណ្តាប់ធ្នាប់ជាអរិយកជាតិនៅឡើយទេ ។

មែនពិតជនជាតិដែលជាម្ចាស់ទឹកដីនេះពីដើម គឺមិលក្ខជាតិ មិនមែនជាអរិយកជាតិទេ ។

តែក្រោយមកពួកអរិយកជាតិ ដែលតាំងទីនៅភូមិភាគខាងជើងភ្នំហិមាល័យនោះ បានចូលមកដេញពួកមិលក្ខជាតិ រួចបានសាងទីក្រុងឈ្មោះកបិលព័ស្តុ នៅក្នុងដងព្រៃម៉ាស័ក ហៅជាវដ្ឋសក្កៈ នាខាងនាយត្រើយស្ទឹងរោហិណី ។

ឯត្រើយខាងអាយស្ទឹងរោហិណី ក៏មានកោលិយជាតិ សាងទីក្រុងឈ្មោះទេវទហៈឬរាមគ្រាមវដ្ឋៈកោលិយៈ នៅនាមាត់ស្ទឹងរោហិណីនោះដែរ ។

ជនជាតិអរិយកៈ ទាំងជាតិកោលិយៈនេះហើយ ដែលជាព្រះញាតិវង្សនៃព្រះសម្ពុទ្ធរបស់យើងនោះ ។

មុនព្រះពុទ្ធកើតទាំងព្រះពុទ្ធកំពុងកើតនោះ ជនជាតិ

www.budinst.gov.kh www.elibraryofcambodia.org

ដំបូងមិនទាន់កាន់ពុទ្ធសាសនាទេ គាត់ច្រើនជាអ្នកអនុវត្តតាំង
តាមតែលទ្ធិព្រាហ្មណសាសនា ហើយប្រកាន់វណ្ណៈណាស់ផង ។

ក្នុងយុគសម័យនោះគេចាត់មនុស្សជា ៤ វណ្ណៈ គឺ:

១. វណ្ណក្សត្រ (អ្នករដ្ឋប្បសាសនាបាយ-យុទ្ធសាស្ត្រ),

២- វណ្ណព្រាហ្មណ៍ (អ្នកបង្ហាត់បង្រៀនទិនវដ្តធម្មសាស្ត្រ),

៣- វេស្សៈ (អ្នកឧស្សាហករនិងពាណិជ្ជករ),

៤- សូទ្រៈ (អ្នកកសិករនិងកម្មករ) ។

វណ្ណៈទាំង៤នេះឆ្ងាយពីគ្នាដូចមេឃនិងដីសម័យនោះ ។ ឧទាហរណ៍ បើពួកណាមួយដូចជាវណ្ណព្រាហ្មណ៍ទៅរួមរស់ជាមួយនឹងវណ្ណសូទ្រៈ លុះមានកូនចៅមកគេចាត់គ្នានោះថា: ជនចណ្ឌាល (អ្នកអាក្រក់ថោកទាប) ។

ការប្រកាន់វណ្ណៈនេះជាប់រហូតដល់មកសម័យពុទ្ធកាល ជំនាន់វិឌូឌកៈ ។ សង្គ្រាមវិឌូឌកៈជាសង្គ្រាមបំបាត់មានះនៃការប្រកាន់វណ្ណៈ, ដូចនេះពួកសក្កៈឬសាក្យៈក្នុងសម័យនោះវិនាសអស់ច្រើនណាស់, ឯខ្លះទៀតដែលរត់រួចក៏ភៀសខ្លួនទៅនៅ

www.budinst.gov.kh www.elibraryofcambodia.org

ឯមោរិយនគរនិងបាដលិបុត្រ ។ល។

ដោយពុទ្ធសាសនាមានធម្មៈត្រឹមតែសមធម៌ចំពោះមនុស្សជាតិនោះទើបពួកពុទ្ធសាសនិក មានសាធារណនាមប្បញ្ញត្តិថា ភិក្ខុនិងភិក្ខុនី ឧបាសកនិងឧបាសិកាតែប៉ុណ្ណោះ ទោះមានវណ្ណៈជាអ្វីក៏ដោយ ។

ក្នុងបរាភវសូត្រនិងវសលសូត្រសុត្តនិបាតខុទ្ទកនិកាយ ព្រះពុទ្ធទ្រង់ចែងថា៖

ជាតិថទ្ធោ ធនថទ្ធោ
គោត្តថទ្ធោ ច យោ នរោ,
សញ្ញាតិំ អតិមញ្ញេតិ
តំ បរាភវតោ មុខំ ។
ន ជច្ចា វសលោ ហោតិ
ន ជច្ចា ហោតិ ព្រាហ្មណោ,
កម្មុនា វសលោ ហោតិ
កម្មុនា ហោតិ ព្រាហ្មណោ ។

www.budinst.gov.kh www.elibraryofcambodia.org

ជនណាប្រកាន់ពូជជាតិ រើសរើសស្រេកទ្រព្យធនធាន ស្ដាំគោត្រត្រកូលសែស្រឡាយ ប្រមាថមើលងាយសាច់ញាតិខ្លួនទីដ៏អ្នកដទៃថាគេមានពូជជាតិជាដើម ជោគទាបមិនស្មើនឹងខ្លួន, នោះឈ្មោះថា: គេកំពុងបំបែរមុខទៅរកក្ដៅ គឺសេចក្ដីវិនាសហិនហោចដោយពិត ។

(តាមពិត)ដែល ហៅថា: ជោគទាបមិនមែនសំដៅយកពូជជាតិជាដើមទេ, ហើយដែលហៅថាប្រសើរខ្ពង់ខ្ពស់ ក៏មិនមែនសំដៅយកពូជជាតិជាដើមដែរ, ដែលហៅថាជោគទាបនោះ សំដៅយកកម្មគឺអំពើអាក្រក់មិនបរិសុទ្ធ ដែលមនុស្សម្នាក់ៗធ្វើទៅតើ, ហើយដែលហៅថាប្រសើរខ្ពង់ខ្ពស់ ក៏សំដៅយកកម្មគឺអំពើល្អបរិសុទ្ធដែលគេធ្វើនោះដែរ ។

ម្យ៉ាងទៀត សូម្បីការចែកលាភ ឬ ការបរិច្ចាគទាន ក៏ពុទ្ធសាសនាឲ្យអនុវត្តតាមសមធម៌ដែរ, មិនឲ្យអនុវត្តជាផ្ដាច់បុគ្គលិកចំពោះបុគ្គលម្នាក់ ៗ ឡើយ, គឺឲ្យគេអនុវត្តជាសាធារណលាភ ឬសាធារណសង្ឃដែលហៅថាសង្ឃលាភ

www.budinst.gov.kh www.elibraryofcambodia.org

ឬសង្ឃទាននោះ ។

ព្រះពុទ្ធទ្រង់ពន្យល់ព្រះមាតាចិញ្ចឹមរបស់ព្រះអង្គ ក្នុងទក្ខិណាវិភង្គសូត្រវណ្ណនាមជ្ឈិមនិកាយថា៖

សំឃេ គោតមិ ទេហិ សំឃេ តេ ទិន្នេ
អហញ្ចេវ បូជិតោ ភវិស្សាមិ សំឃោ ចាតិ ។

បពិត្រព្រះមហាបជាបតីគោតមី! សូមព្រះនាងបរិច្ចាគទាន ជាសាធារណៈចំពោះព្រះសង្ឃចុះ កាលបើព្រះនាងបានបរិច្ចាគទាន ជាសាធារណៈចំពោះព្រះសង្ឃហើយ ទុកជាតថាគតក្តី ព្រះសង្ឃក្តី ក៏ឈ្មោះថាព្រះនាងគោរពបូជាហើយដែរ ។

ដ្បិតសាសនារបស់តថាគត រមែងឋិតនិងឋិតនៅលើព្រះភិក្ខុសង្ឃ មិនមែនឋិតនៅអស់បរិកាល លើតថាគតម្នាក់ឯងនោះទេ ។

បកិណ្ណកកថាចប់

www.budinst.gov.kh www.elibraryofcambodia.org

ឈ្មោះលោកអ្នកមានសទ្ធាជ្រះថ្លាចូលរួម
បោះពុម្ពសៀវភៅ "ប្រវត្តិពុទ្ធសាសនានៅក្រោយព្រះពុទ្ធ
បរិនិព្វាន" ចំនួន មួយពាន់ "១.០០០" ក្បាល :

| | |
|---|---|
| - ឯ.ឧ. ហង់ ថួន និង លោកជំទាវ | ២០ ដុល្លារ |
| - លោក លុត សិលា និងអ្នកស្រី កៀត សុទ្ធារី<br>- អ្នកម្តាយ សាំង ឈាង<br>- អ្នកម្តាយ ហុក សាទៀស | ១.០០០ បាត<br>១០.០០០ រៀល |
| - លោក វេជ្ជហ៊ុនប៉ន និង លោកស្រី | ៣២ ដុល្លារ |
| - លោក ហង់ ចន្ទ និង លោកស្រី | ១០ 〃 |
| - លោក ឈាន ឃោ និង លោកស្រី | ២០ 〃 |
| - លោក ផាន់ សុក និង បុត្រ | ១០ 〃 |
| - លោក សិម ស៊ីផន និងលោកស្រី | ១០ 〃 |
| - លោក គិក សេងភន និងលោកស្រី | ៥ 〃 |
| - លោក ម៉ម សេង និងលោកស្រី | ៥ 〃 |
| - លោក ម៉ៅ ប៊ុន និងលោកស្រីនិងបុត្រ | ១០ 〃 |
| - លោកតា ឈាម រឿន | ១៥ 〃 |
| - លោកតា ម៉ៅ ផា | ៥ 〃 |
| - លោក ម៉ៅ បុញ្ញ ខេត្តនិងលោកស្រីផា ស្រីយមុនី | ៥ 〃 |
| - លោក [illegible] និងលោកស្រី | ១០ 〃 |
| - លោកយាយ ប្រាក់ ឃីន ព្រមទាំងបុត្រ | ១០ 〃 |
| - លោក សេន ស៊ីថា និងអ្នកស្រី ភុន សារុំ | ១០ 〃 |
| - លោក ប្រាក់ ប៊ុនរិទ្ធ និងអ្នកស្រី ច័ន្ទ មាលី | ១០ 〃 |
| - លោក ធាង ហេង | ១០ 〃 |
| - អ្នកស្រី តាន់ សុខណា និង បុត្រ | ១០ 〃 |
| - អ្នកស្រី ព្រុំ កាទី និង បុត្រ | ១០ 〃 |
| - លោក [illegible] និងលោកស្រី | ៥ 〃 |

www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| -លោក ប៊ុន សម្បូរនិងលោកស្រីម៉ៅ អៀងបុទ្ធា | ៥ ដុល្លា |
| -លោក រ័ត ដួងតារានិងលោកស្រីម៉ៅអៀងបុទ្ធិ | ៥ - |
| -លោកតា រ័កវ៉ ភួង | ៣.០០០រ |
| -លោកតា លឹាង ទក | ៧.៥០០រ |
| -លោកតា វស់ ផាន | ៥.០០០រ |
| -លោកតា កួយ ឈួន | ៣.០០០រ |
| -លោក វ័ប៉ឺន វ័អម | ៥.០០០រ |
| -លោកតា ទៀង សួង | ១០.០០០រ |
| - ពុទ្ធបរិស័ទ វត្ត សង្ឃ័រកុសល | ១៥.៥០០រ |
| ពុទ្ធបរិស័ទ វត្ត ស័ពៅមាស | |
| -លោក រឹង សាបូរ | ២០.០០០រ |
| -អ្នកស្រី អ៊ុង ស៊ីវឆេង | ៤០.០០០រ |
| -លោកយាយ ផាំង ស្រ៊ុង | ១២.០០០រ |
| -អ្នកស្រី សុខ លីម | ៨.០០០រ |
| -លោកយាយ ផា ស៊ីម | ៦.០០០រ |
| -លោកតា សៅ សុច | ៣.២០០រ |
| -លោក តាំង ង៉ួន | ៥.០០០រ |
| -លោកយាយ តាំង ស៊ីម | ២.០០០រ |
| -លោក ឡាំង សុងហេង | ៣.០០០រ |
| -លោកយាយ ប៉ុម សុខុម | ៥.០០០រ |
| -លោកយាយ អ៊ឹក ស៊ីធួន | ៤.០០០រ |
| -លោកយាយ ឈឹម អ៊ឹម | ៤.០០០រ |
| -លោកយាយ កាំង ថ្លឹង | ២.៥០០រ |
| -លោកយាយ តួច វ៉ាន | ៤.០០០រ |
| -លោកយាយ ប្រាក់ រី | ៥.០០០រ |

www.budinst.gov.kh www.elibraryofcambodia.org

- លោកយាយ ឡាយ ឡាច ៥.០០០៛០០
- លោកយាយ អោប ប៊ិន ៥.០០០៛០០
- លោកយាយ ទីវ ម៉ៅ ៤.០០០៛០០
- លោកយាយ ឈី សៀន ៤.០០០៛០០

យើងខ្ញុំទាំងអស់គ្នាសូមថ្វាយបង្គំ នូវ

ព្រះរតនត្រ័យទាំងបី ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រមទាំងសម្តេចព្រះធម្មលិខិត លាស់ ឡាយ ហើយនិងសូមឧទ្ទិសផលបុណ្យផល ដែលកើតឡើងអំពីកុសលកម្មដ៏វិសេស គឺ ការបោះពុម្ពសៀវភៅចែកជាធម្មទានខាងលើនេះ ជូនចំពោះឧបការីជន មានមាតាបិតាជាដើម ជីដូន ជីតា ញាតិកាប្រាំពីរសន្តាន គ្រូឧបជ្ឈាយាចារ្យ បុព្វបុរសវីរជន ស្នេហាជាតិដែលបានធ្វើមរណកាលទៅ ទោះស្ថិតនៅភពណាក៏ដោយ ឬ ដែលរស់នៅសព្វថ្ងៃ សូមឲ្យលោកបានទទួល នូវភាគផល កុសលរាសី ធម្មទានរៀង ៗ ខ្លួនសព្វ ៗ កាល កុំបីឃ្លៀងឃ្លាតឡើយ ។

ម្យ៉ាងទៀត យើងខ្ញុំសូមនិងកាយអនុញ្ញាតថ្លែងអំណរ ព្រះគុណដ៏បវរចំពោះសម្តេចព្រះធម្មលិខិត ដែលទ្រង់បានមេត្តាអនុញ្ញាតអោយយើងខ្ញុំនាំគ្នាធ្វើការបោះពុម្ពសៀវភៅ ប្រវត្តិពុទ្ធសាសនាក្រោយព្រះពុទ្ធបរិនិព្វាន ភាគ ៤ ធម្មទាន ចែកឆ្ងាយលើកនេះ និង លើកមុនៗ ជាទានមានផលយ៉ាង វិសេសក្នុងការតបស្នងសងឧបការគុណរបស់មាតាបិតា ដែលអាច នាំទុកមកជាធម៌កតញ្ញូកតវេទីមួយបែប មួយបែបទៀតក្នុងការ បដិបត្តាតបស្នងបោះពុម្ពសៀវភៅនេះសារថ្មី យើងខ្ញុំមានបំណង

www.budinst.gov.kh www.elibraryofcambodia.org

ប្រាថ្នា តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ជាហិតានុហិត ប្រយោជន៍ដល់ជនានុជន ។

ជាទីបញ្ចប់ យើងខ្ញុំសូមឱនកាយអនុញ្ញាតប្រគេនពរមហាប្រសើរ និង ឧទ្ទិសកុសលបវរប្រគេនសម្តេចព្រះធម្មលិខិត សូមសម្តេចទ្រង់គង់នៅយូរអង្វែងជាម្លប់ ប្រកបតាមពុទ្ធពរ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ៕

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org